ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និង ការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ



ខែមីនា ឆ្នាំ២០២០

## មាតិកា


បុព្វកថា ......... 1

ផ្នែកទី១. បទប្បញ្ញត្តិទូទៅ ......... 2

មាត្រា១. ការប្រើវាក្យសព្ទនិងវិសាលភាព ......... 2

មាត្រា២. គោលដៅ ......... 2

មាត្រា៣. ការអនុវត្ត ......... 2

មាត្រា៤. ទំនាក់ទំនងរវាងកិច្ចព្រមព្រៀងនេះនិងអនុសញ្ញា ......... 3

ផ្នែកទី២. ការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ......... 3

មាត្រា៥. គោលការណ៍ទូទៅ ......... 3

មាត្រា៦. ការអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន ......... 4

មាត្រា៧. ភាពស្របគ្នានៃវិធានការគ្រប់គ្រងនិងអភិរក្ស ......... 5

ផ្នែកទី៣.យន្តការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ......... 7

មាត្រា៨. កិច្ចសហប្រតិបត្តិការសម្រាប់ការគ្រប់គ្រងនិងការអភិរក្ស ......... 7

មាត្រា៩. អង្គការនិងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់ ......... 8

មាត្រា១០. ការប្រព្រឹត្តទៅរបស់អង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់ ......... 9

មាត្រា១១. សមាជិកឬអ្នកចូលរួមថ្មី ......... 10

មាត្រា១២.តម្លាភាពនៅក្នុងសកម្មភាពរបស់អង្គការនិងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់ ......... 10

មាត្រា១៣. ការពង្រឹងអង្គការនិងក្រុមការងារដែលមានស្រាប់ ......... 10

មាត្រា១៤.ការប្រមូលនិងផ្តល់ព័ត៌មាននិងកិច្ចសហប្រតិបត្តិការក្នុងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ......... 11

មាត្រា១៥. សមុទ្រក្នុងនិងឈូងសមុទ្រ ......... 11

មាត្រា១៦.តំបន់សមុទ្រអន្តរជាតិព័ទ្ធជុំវិញទាំងស្រុងដោយតំបន់សមុទ្រស្ថិតនៅក្រោមដែនយុត្តាធិការនៃរដ្ឋទោលមួយ ......... 11

ផ្នែកទី៤.រដ្ឋមិនមែនជាសមាជិកនិងរដ្ឋមិនមែនជាអ្នកចូលរួម ......... 12

មាត្រា១៧.រដ្ឋមិនមែនជាសមាជិករបស់អង្គការនិងរដ្ឋមិនមែនជាអ្នកចូលរួមនៅក្នុងក្រុមការងារ ......... 12

ផ្នែកទី៥. កាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ ......... 13

មាត្រា១៨. កាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ ......... 13

ផ្នែកទី៦. ការគោរពនិងការអនុវត្តច្បាប់ ......... 14

មាត្រា១៩. ការគោរពនិងការអនុវត្តច្បាប់ដោយរដ្ឋម្ចាស់ទង់ជាតិ ......... 14

មាត្រា២០. កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការអនុវត្តច្បាប់ ......... 15

មាត្រា២១. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអនុតំបន់ក្នុងការអនុវត្តច្បាប់ ......... 16

មាត្រា២២. នីតិវិធីជាមូលដ្ឋានសម្រាប់ការឡើងនិងការធ្វើអធិការកិច្ចលើនាវាស្របតាម ......... 19

មាត្រា២៣. វិធានការដែលត្រូវប្រកាន់យកដោយរដ្ឋម្ចាស់កំពង់ផែ ......... 20

ផ្នែកទី៧. តម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍ ......... 21

មាត្រា២៤. ការទទួលស្គាល់តម្រូវការពិសេសរបស់រដ្ឋកំពុងអភិវឌ្ឍ 21
មាត្រា២៥. ទម្រង់នៃកិច្ចសហការជាមួយរដ្ឋកំពុងអភិវឌ្ឍ 21
មាត្រា២៦. ជំនួយពិសេសក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ 22
ផ្នែកទី៨. ការដោះស្រាយវិវាទដោយសន្តិវិធី 22
មាត្រា២៧. កាតព្វកិច្ចដើម្បីដោះស្រាយវិវាទដោយសន្តិវិធី 22
មាត្រា២៨. ការបង្ការវិវាទ 22
មាត្រា២៩. វិវាទផ្នែកបច្ចេកទេស 22
មាត្រា៣០. នីតិវិធីដោះស្រាយវិវាទ 22
មាត្រា៣១. វិធានការបណ្ដោះអាសន្ន 23
មាត្រា៣២. ដែនកំណត់ស្ដីពីនីតិវិធីដែលអាចអនុវត្តបានក្នុងការដោះស្រាយវិវាទ 24
ផ្នែកទី៩. ភាគីមិនមែនជាសមាជិកក្នុងកិច្ចព្រមព្រៀង 24
មាត្រា៣៣. ភាគីមិនមែនជាសមាជិកក្នុងកិច្ចព្រមព្រៀង 24
ផ្នែកទី១០. ការជឿទុកចិត្តនិងការរំលោភសិទ្ធិ 24
មាត្រា៣៤. ការជឿទុកចិត្តនិងការរំលោភសិទ្ធិ 24
ផ្នែកទី១១. ភារកិច្ចនិងភាពទទួលខុសត្រូវ 24
មាត្រា៣៥. ភារកិច្ចនិងភាពទទួលខុសត្រូវ 24
ផ្នែកទី១២. សន្និសីទពិនិត្យឡើងវិញ 24
មាត្រា៣៦. សន្និសីទពិនិត្យឡើងវិញ 24
ផ្នែកទី១៣. អវសានប្បញ្ញត្តិ 25
មាត្រា៣៧. ការចុះហត្ថលេខា 25
មាត្រា៣៨. ការផ្ដល់សច្ចាប័ន 25
មាត្រា៣៩. ការចូលជាសមាជិក 25
មាត្រា៤០. ការចូលជាធរមាន 25
មាត្រា៤១. ការអនុវត្តបណ្ដោះអាសន្ន 25
មាត្រា៤២. ការបម្រុងទុកនិងការលើកលែង 26
មាត្រា៤៣. សេចក្ដីប្រកាសនិងសេចក្ដីថ្លែងការណ៍ 26
មាត្រា៤៤. ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងផ្សេងទៀត 26
មាត្រា៤៥. វិសោធនកម្ម 26
មាត្រា៤៦. ការប្ដឹងជំទាស់ 27
មាត្រា៤៧.ការចូលរួមដោយអង្គការអន្តរជាតិ 27
មាត្រា៤៨. ឧបសម្ព័ន្ធ 28
មាត្រា៤៩.អ្នកតម្កល់ឯកសារ 28
មាត្រា៥០.យថាភូតភាពនៃកិច្ចព្រមព្រៀង 28
ឧបសម្ព័ន្ធទី១.តម្រូវការស្តង់ដារសម្រាប់ការប្រមូលនិងការចែករំលែកទិន្នន័យ 30
មាត្រា១. គោលការណ៍ទូទៅ 30

មាត្រា២. គោលការណ៍នៃការប្រមូល ការចងក្រង និងការផ្លាស់ប្តូរទិន្នន័យ ..........................................30
មាត្រា៣. ទិន្នន័យជលផលជាមូលដ្ឋាន ..........................................................................................31
មាត្រា៤. ទិន្នន័យនិងព័ត៌មាននាវានេសាទ ....................................................................................31
មាត្រា៥. ការរាយការណ៍ ...........................................................................................................31
មាត្រា៦. ការផ្ទៀងផ្ទាត់ទិន្នន័យ ...................................................................................................32
មាត្រា៧. ការផ្លាស់ប្តូរទិន្នន័យ .....................................................................................................32
ឧបសម្ព័ន្ធទី២.គោលការណ៍ណែនាំសម្រាប់អនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន ក្នុងការគ្រប់គ្រង និងអភិរក្ស ផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ ..................................................................34
ឧបសម្ព័ន្ធទី៣.ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ..........................................................................................................34

## បុព្វកថា

# រដ្ឋភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ

**ដោយរំលឹកឡើងវិញ**នូវបទប្បញ្ញត្តិពាក់ព័ន្ធនានានៃអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៨២។

**ដោយកំណត់ក្នុងការធានា**ដល់ការអភិរក្សយូរអង្វែងនិងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

**ដោយមានការសម្រេចចិត្ត** ដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការរវាងរដ្ឋនានាក្នុងគោលដៅរួម។

**ដោយអំពាវនាវ**ឱ្យមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋម្ចាស់ទង់ជាតិ រដ្ឋម្ចាស់កំពង់ផែ និងរដ្ឋម្ចាស់ឆ្នេរលើវិធានការគ្រប់គ្រងនិងអភិរក្សដែលបានអនុម័តសម្រាប់ផលស្តុកទាំងនោះ។

**ដោយស្វែងរកដំណោះស្រាយ**ក្នុងការឆ្លើយតបនឹងបញ្ហា ជាពិសេស បញ្ហាដែលបានកំណត់នៅក្នុងជំពូក១៧ កម្មវិធី "គ" នៃរបៀបវារៈ២១ដែលបានអនុម័តដោយសន្និសីទសហប្រជាជាតិស្តីពីបរិស្ថាននិងការអភិវឌ្ឍ ដូចជាការគ្រប់គ្រងជលផលនៅក្នុងដែនសមុទ្រអន្តរជាតិនៅមានភាពខ្វះចន្លោះនៅក្នុងតំបន់ជាច្រើន ហើយធនធានមួយចំនួនត្រូវបានប្រើប្រាស់ហួសកម្រិត។ ដោយកត់សម្គាល់ឃើញថាមានបញ្ហាជាច្រើនដូចជា ការនេសាទដោយគ្មានការអនុញ្ញាត ការប្រើប្រាស់មូលធនហួសកម្រិត ចំនួននាវានេសាទច្រើនហួសកម្រិត នាវាដែលប្តូរទង់ជាតិដើម្បីគេចចេញពីការត្រួតពិនិត្យ ឧបករណ៍នេសាទជ្រើសរើសគោលដៅមិនទាន់បានរៀបចំល្អ ទិន្នន័យមូលដ្ឋានដែលមិនអាចជឿជាក់បាន និងកង្វះកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ។

**ដោយប្តេជ្ញាចិត្ត**ពីរដ្ឋសាមីទាំងអស់ក្នុងការធ្វើនេសាទប្រកបដោយការទទួលខុសត្រូវ។

**ដោយមនសិការយល់ឃើញ**ពីតម្រូវការនៃការបញ្ចៀសផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ ទៅលើបរិស្ថានសមុទ្រ ការរក្សាជីវៈចម្រុះ ការថែរក្សាប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងការកាត់បន្ថយជាអប្បបរមានូវហានិភ័យនៃផលប៉ះពាល់យូរអង្វែងឬមិនអាចស្តារផលប៉ះពាល់នៃការធ្វើនេសាទ។

**ដោយទទួលស្គាល់**នូវតម្រូវការសម្រាប់ជំនួយជាក់លាក់រាប់បញ្ចូលទាំងជំនួយផ្នែកហិរញ្ញវត្ថុ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដល់រដ្ឋកំពុងអភិវឌ្ឍអាចចូលរួមគ្រប់គ្រង អភិរក្ស និងប្រើប្រាស់ផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

**ដោយមានការជឿជាក់**ថាកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញា នឹងបម្រើដល់គោលបំណងទាំងអស់ឱ្យល្អប្រសើរ និងចូលរួមចំណែកដល់ការថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ។

**ដោយអះអាងថា**បញ្ហានានាដែលមិនបានកំណត់ក្នុងអនុសញ្ញាឬកិច្ចព្រមព្រៀងនេះ នឹងបន្តគ្រប់គ្រងដោយច្បាប់ និងគោលការណ៍ច្បាប់អន្តរជាតិទូទៅ។

បានព្រមព្រៀងគ្នាដូចតទៅ៖

## ផ្នែកទី១. បទប្បញ្ញត្តិទូទៅ

### មាត្រា១. ការប្រើវាក្យសព្ទនិងវិសាលភាព

១. សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ វាក្យសព្ទខាងក្រោមមានន័យដូចតទៅ៖

(ក) "**អនុសញ្ញា**" មានន័យថាអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២

(ខ)"**វិធានការគ្រប់គ្រងនិងអភិរក្ស**" មានន័យថា វិធានការទាំងឡាយសម្រាប់គ្រប់គ្រង និងអភិរក្សប្រភេទធនធានសមុទ្រមានជីវិតមួយឬច្រើន ដែលត្រូវបានអនុម័តនិងអនុវត្តដោយមានសង្គតិភាពជាមួយនឹងវិធាននៃច្បាប់អន្តរជាតិពាក់ព័ន្ធ ដូចមានចែងក្នុងអនុសញ្ញានិងកិច្ចព្រមព្រៀងនេះ

(គ) "**ត្រី**" រាប់បញ្ចូលទាំងសិប្បីសត្វនិងពពួកក្តាម លើកលែងតែពពួកដែលស្ថិតក្នុងប្រភេទដែលមិនធ្វើបម្លាស់ទី ដូចបានកំណត់ក្នុងមាត្រា៧៧នៃអនុសញ្ញា

(ឃ) "**ការរៀបចំ**" មានន័យថា យន្តការសហប្រតិបត្តិការមួយដែលបានបង្កើតឡើងស្របតាមអនុសញ្ញានិងកិច្ចព្រមព្រៀងនេះដោយរដ្ឋពីរឬច្រើន ក្នុងគោលបំណងដូចជាការបង្កើតវិធានការគ្រប់គ្រងនិងអភិរក្សនានាក្នុងតំបន់ឬអនុតំបន់មួយ ដែលប្រើសម្រាប់ផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយតែមួយប្រភេទឬច្រើនប្រភេទ

២. (ក) "**រដ្ឋភាគី**" មានន័យថា រដ្ឋទាំងឡាយណាដែលបានយល់ព្រមនិងមានកាតព្វកិច្ចអនុវត្តកិច្ចព្រមព្រៀងនេះ ហើយកិច្ចព្រមព្រៀងនេះត្រូវស្ថិតជាធរមានសម្រាប់រដ្ឋនោះ

(ខ) ក្នុងករណីចាំបាច់ បើមានការកែសម្រួលមិនឱ្យប៉ះពាល់ដល់អត្ថន័យដើម កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះ៖

(i) អង្គភាពណាមួយដែលមានចែងក្នុងមាត្រា៣០៥ កថាខណ្ឌទី១ (គ) (ឃ) និង (ង) នៃអនុសញ្ញា

(ii)ផ្អែកលើមាត្រា៤៧ សំដៅដល់អង្គភាពណាមួយដែលជាអង្គការអន្តរជាតិមួយដែលមានចែងក្នុងឧបសម្ព័ន្ធ៩ មាត្រា១នៃអនុសញ្ញា ដែលបានក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះ និង"រដ្ឋភាគី" សំដៅដល់អង្គភាពទាំងនោះ។

៣. កិច្ចព្រមព្រៀងនេះអនុវត្តដោយមានការកែសម្រួល មិនឱ្យប៉ះពាល់ដល់អត្ថន័យដើម ក្នុងករណីចាំបាច់ចំពោះអង្គភាពនេសាទដទៃទៀតដែលនាវារបស់ពួកគេធ្វើនេសាទនៅសមុទ្រអន្តរជាតិ។

### មាត្រា២. គោលដៅ

គោលដៅនៃកិច្ចព្រមព្រៀងនេះ គឺធានាដល់ការអភិរក្សយូរអង្វែងនិងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទប្បញ្ញត្តិពាក់ព័ន្ធនានានៃអនុសញ្ញា។

### មាត្រា៣. ការអនុវត្ត

១. លើកលែងតែមានការចែងផ្ទុយពីនេះ កិច្ចព្រមព្រៀងនេះអនុវត្តសម្រាប់ការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៅក្នុងតំបន់ហួសពីដែនយុត្តាធិការជាតិ លើកលែងតែមាត្រា៦និងមាត្រា៧ ដែលអនុវត្តចំពោះការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីខាងលើនៅក្រោមតំបន់ស្ថិតក្នុងដែនយុត្តា

ធិការជាតិអាស្រ័យនឹងច្បាប់ផ្សេងៗគ្នាដែលអនុវត្តនៅក្នុងតំបន់ក្រោមដែនយុត្តាធិការជាតិ និងនៅក្នុងតំបន់ក្រៅពីដែនយុត្តាធិការជាតិ ដូចមានចែងនៅក្នុងអនុសញ្ញា។

២. ក្នុងការអនុវត្តសិទ្ធិអធិបតេយ្យភាពជាតិក្នុងគោលបំណងរុករកនិងធ្វើអាជីវកម្ម គ្រប់គ្រងនិងអភិរក្ស ផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ រដ្ឋម្ចាស់ឆ្នេរនឹងអនុវត្តគោលការណ៍ទូទៅ ដោយមានការកែសម្រួលមិនឱ្យប៉ះពាល់ដល់អត្ថន័យដើមក្នុងករណីចាំបាច់ដូចមានចែងក្នុងមាត្រា៥។

៣. រដ្ឋនានាត្រូវពិចារណាឱ្យបានត្រឹមត្រូវលើសមត្ថភាពនៃរដ្ឋកំពុងអភិវឌ្ឍ ដើម្បីអនុវត្តមាត្រា៥ មាត្រា៦ និងមាត្រា៧នៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ និងលើសេចក្តីត្រូវការជំនួយរបស់រដ្ឋទាំងនោះ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។ដើម្បីសម្រេចបាននូវទិសដៅនេះផ្នែក៧ នឹងអនុវត្តដោយមានការកែសម្រួលមិនឱ្យប៉ះពាល់ដល់អត្ថន័យដើម ក្នុងករណីចាំបាច់ ចំពោះតំបន់ស្ថិតនៅក្រោមដែនយុត្តាធិការជាតិ។

## មាត្រា៤. ទំនាក់ទំនងរវាងកិច្ចព្រមព្រៀងនេះនិងអនុសញ្ញា

គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះដែលបង្កព្យសនកម្មចំពោះសិទ្ធិ យុត្តាធិការ និងករណីយកិច្ចរបស់រដ្ឋនៅក្នុងអនុសញ្ញា។ កិច្ចព្រមព្រៀងនេះនឹងត្រូវបកស្រាយនិងអនុវត្តក្នុងបរិបទ ដោយមានសង្គតិភាពជាមួយអនុសញ្ញា។

# ផ្នែកទី២. ការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

## មាត្រា៥. គោលការណ៍ទូទៅ

ដើម្បីគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ និងបង្កើនប្រសិទ្ធភាពការងារក្នុងកិច្ចសហប្រតិបត្តិការឱ្យស្របតាមអនុសញ្ញា រដ្ឋម្ចាស់ឆ្នេរនិងរដ្ឋដែលធ្វើនេសាទនៅដែនសមុទ្រអន្តរជាតិត្រូវ៖

(ក) អនុម័តវិធានការដើម្បីធានានិរន្តរភាពយូរអង្វែងនៃផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ និងលើកកម្ពស់គោលបំណងនៃការប្រើប្រាស់ផលស្តុកត្រីទាំងនោះឱ្យបានល្អបំផុត

(ខ) ធានាថាវិធានការទាំងនោះ គឺផ្អែកទៅលើភស្តុតាងវិទ្យាសាស្រ្តប្រសើរបំផុតដែលមាននិងត្រូវបានរៀបចំឡើងសម្រាប់ថែរក្សាឬស្តារផលស្តុកត្រីទាំងនោះឡើងវិញ នៅកម្រិតដែលអាចផលិតបាននូវទិន្នផលនិរន្តរភាពអតិបរមា ដែលសមស្របតាមកត្តាសេដ្ឋកិច្ចនិងបរិស្ថានពាក់ព័ន្ធដោយរាប់បញ្ចូលទាំងតម្រូវការពិសេសរបស់រដ្ឋកំពុងអភិវឌ្ឍនិងគិតទៅដល់បែបផែននៃការធ្វើនេសាទការពឹងអាស្រ័យគ្នាទៅវិញទៅមកនៃផលស្តុកត្រី និងស្តង់ដារអន្តរជាតិអប្បបរមាដែលបានណែនាំជាទូទៅសម្រាប់ថ្នាក់អនុតំបន់ តំបន់ ឬសកល

(គ) អនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន ស្របតាមមាត្រា៦

(ឃ) វាយតម្លៃផលប៉ះពាល់ពីការធ្វើនេសាទ សកម្មភាពផ្សេងៗរបស់មនុស្ស និងកត្តាបរិស្ថានទៅលើផលស្តុកគោលដៅនិងប្រភេទត្រី ស្ថិតក្នុងប្រព័ន្ធអេកូឡូស៊ីតែមួយឬមានទំនាក់ទំនងជាមួយគ្នាឬពឹងអាស្រ័យលើផលស្តុកគោលដៅ

(ង) ក្នុងករណីចាំបាច់ អនុម័តវិធានការគ្រប់គ្រងនិងអភិរក្សសម្រាប់ប្រភេទដែលស្ថិតនៅក្នុងប្រព័ន្ធអេកូឡូស៊ីដូចគ្នា ឬមានទំនាក់ទំនងជាមួយគ្នា ឬពឹងអាស្រ័យលើផលស្តុកគោលដៅ ដោយឈរលើ ទស្សនៈថែ

រក្សានិងស្តារឡើងវិញនូវបរិមាណនៃប្រភេទត្រីទាំងនោះ ឱ្យមានកម្រិតខ្ពស់លើសពីកម្រិតនៃការបន្តពូជរបស់ពួកវាដែលអាចស្ថិតក្នុងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ

(ច) កាត់បន្ថយឱ្យដល់កម្រិតអប្បបរមានូវការបំពុល កាកសំណល់ ការបោះចោល ការជាប់ត្រីដោយឧបករណ៍នេសាទបោះបង់ចោល ផលនេសាទដែលមិនមែនជាប្រភេទគោលដៅនៃការធ្វើនេសាទ ទាំងជាប្រភេទត្រី ទាំងពពួកមិនមែនជាប្រភេទត្រី (កំណត់ថាមិនមែនជាប្រភេទគោលដៅ) និងផលប៉ះពាល់លើប្រភេទត្រីពាក់ព័ន្ធឬប្រភេទត្រីដែលពឹងអាស្រ័យ ជាពិសេស ប្រភេទត្រីដែលកំពុងរងគ្រោះ តាមរយៈវិធានការទាំងឡាយ តាមលទ្ធភាពដែលអាចអនុវត្តបាន ដូចជាការបង្កើតនិងការប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសនេសាទចាប់ប្រភេទត្រីគោលដៅ ដោយមិនប៉ះពាល់ដល់បរិស្ថាននិងមានប្រសិទ្ធភាពស្របនឹងតម្លៃ

(ឆ) ការពារជីវៈចម្រុះនៅក្នុងបរិស្ថានសមុទ្រ

(ជ) ចាត់វិធានការដើម្បីការពារឬលុបបំបាត់ការនេសាទហួសកម្រិត និងសមត្ថភាពនេសាទហួសកម្រិត ដើម្បីធានាថាកម្រិតនៃការនេសាទមិនលើសពីកម្រិតដែលសមាមាត្រ នឹងការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព

(ឈ) យកចិត្តទុកដាក់ទៅលើផលប្រយោជន៍របស់អ្នកនេសាទជាលក្ខណៈប្រពៃណី និងអ្នកនេសាទគ្រួសារ

(ញ) ប្រមូលនិងចែករំលែកឱ្យទាន់ពេលវេលានូវទិន្នន័យ ដែលទាក់ទងទៅនឹងសកម្មភាពនេសាទឱ្យបានច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ មានជាអាទិ៍ ទីតាំងនាវា ផលនេសាទនៃប្រភេទត្រីគោលដៅនិងមិនមែនគោលដៅ និងសមត្ថភាពនេសាទ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ ក៏ដូចជាព័ត៌មានដែលបានពីកម្មវិធីស្រាវជ្រាវជាតិនិងអន្តរជាតិ

(ដ) លើកកម្ពស់និងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ព្រមទាំងអភិវឌ្ឍបច្ចេកវិទ្យាសមស្របក្នុងការគាំទ្រដល់ការគ្រប់គ្រងនិងការអភិរក្សជលផល

(ឋ) អនុវត្តនិងពង្រឹងវិធានការគ្រប់គ្រងនិងអភិរក្សតាមរយៈការតាមដាន ត្រួតពិនិត្យ និងអង្កេតប្រកបដោយប្រសិទ្ធភាព។

## មាត្រា៦. ការអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន

១. រដ្ឋនានាត្រូវអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុនឱ្យបានទូលំទូលាយដើម្បីគ្រប់គ្រង អភិរក្ស និងធ្វើអាជីវកម្មផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ដើម្បីការពារធនធានសមុទ្រមានជីវិតនិងថែរក្សាបរិស្ថានសមុទ្រ។

២. រដ្ឋនានាត្រូវប្រុងប្រយ័ត្នខ្ពស់នៅពេលដែលមានព័ត៌មានមិនជាក់លាក់ មិនអាចជឿជាក់បាន ឬមិនគ្រប់គ្រាន់។ អវត្តមាននៃព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់មិនត្រូវបានប្រើជាមូលហេតុសម្រាប់ការពន្យារឬការបដិសេធលើការចាត់វិធានការគ្រប់គ្រងនិងអភិរក្សនោះទេ។

៣. ក្នុងការអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន រដ្ឋនានាត្រូវៈ

(ក) ធ្វើឱ្យប្រសើរឡើងនូវការធ្វើសេចក្តីសម្រេចចិត្តសម្រាប់ការគ្រប់គ្រង និងការអភិរក្សធនធានជលផលតាមរយៈការទទួលបាន និងការចែករំលែកព័ត៌មានវិទ្យាសាស្ត្រដ៏ប្រសើរបំផុតដែលមាន និងអនុវត្តបច្ចេកទេសដែលត្រូវបានកែលម្អឱ្យប្រសើរឡើង ក្នុងការដោះស្រាយឬឆ្លើយតបនឹងហានិភ័យ និងភាពមិនប្រាកដប្រជា

(ខ) អនុវត្តគោលការណ៍ណែនាំដែលបានចែងនៅក្នុងតារាងឧបសម្ព័ន្ធ២ និងកំណត់បរិមាណផលស្តុកនៃប្រភេទគោលដៅដែលអនុញ្ញាតឱ្យចាប់ ព្រមទាំងចាត់វិធានការ ប្រសិនបើការនេសាទលើសពីបរិមាណផលស្តុកនៃប្រភេទគោលដៅបានកំណត់នោះ ដោយផ្អែកលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រដ៏ប្រសើរបំផុតដែលមាន

(គ) ពិចារណាលើភាពមិនជាក់លាក់ដែលទាក់ទងទៅនឹងទំហំនិងផលិតភាពនៃផលស្តុក បរិមាណផលស្តុកគោល ស្ថានភាពផលស្តុកដែលទាក់ទងទៅនឹងបរិមាណផលស្តុកគោល កម្រិត និងរបាយត្រីដែលងាប់ដោយការធ្វើនេសាទ និងផលប៉ះពាល់នៃសកម្មភាពនេសាទលើប្រភេទមិនមែនគោលដៅនិងប្រភេទពាក់ព័ន្ធឬពឹងអាស្រ័យ ក៏ដូចជាស្ថានភាពសាគរសាស្ត្រ សេដ្ឋកិច្ច និងបរិស្ថានដែលបានព្យាករនិងមានស្រាប់

(ឃ) រៀបចំកម្មវិធីស្រាវជ្រាវនិងប្រមូលទិន្នន័យសម្រាប់វាយតម្លៃផលប៉ះពាល់ ការធ្វើនេសាទចំពោះប្រភេទមិនមែនគោលដៅ ប្រភេទពាក់ព័ន្ធឬពឹងអាស្រ័យ និងបរិស្ថានរបស់ប្រភេទទាំងនោះ ព្រមទាំងអនុម័តផែនការចាំបាច់ ដើម្បីធានាដល់ការអភិរក្សប្រភេទទាំងនោះ និងការការពារទីជម្រកដែលមានសារៈសំខាន់ជាពិសេស។

៤. រដ្ឋនានាត្រូវចាត់វិធានការដើម្បីធានាថាការនេសាទទាំងនោះនឹងមិនលើសពីផលស្តុកគោលឡើយ។ ខណៈដែលការនេសាទទាំងអស់នោះលើសពីផលស្តុកគោល រដ្ឋនានាត្រូវចាត់វិធានការភ្លាមៗដោយមិនពន្យារពេលដូចដែលបានកំណត់ក្នុងកថាខណ្ឌ៣ (ខ) ដើម្បីស្តារផលស្តុកនោះឡើងវិញ។

៥. នៅពេលដែលស្ថានភាពផលស្តុកត្រីគោលដៅឬមិនមែនគោលដៅ ឬប្រភេទពាក់ព័ន្ធ ឬប្រភេទពឹងអាស្រ័យដល់កម្រិតព្រួយបារម្ភ រដ្ឋនានាត្រូវយកផលស្តុកនិងប្រភេទត្រីទាំងនោះធ្វើជាប្រធានបទសម្រាប់ពង្រឹងការតាមដានដើម្បីពិនិត្យឡើងវិញនូវស្ថានភាពរបស់វានិងប្រសិទ្ធភាពនៃវិធានការគ្រប់គ្រងនិងអភិរក្ស។ រដ្ឋទាំងនោះត្រូវកែលម្អវិធានការទាំងនោះជាប្រចាំក្នុងពេលដែលមានព័ត៌មានថ្មីៗ។

៦. សម្រាប់របកគំហើញជលផលថ្មី រដ្ឋនានាត្រូវអនុម័តឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននូវវិធានការគ្រប់គ្រង និងអភិរក្សដោយប្រុងប្រយ័ត្ន មានដូចជាការកម្រិតបរិមាណផលចាប់និងការកម្រិតសមត្ថភាពនេសាទ។ វិធានការទាំងនោះត្រូវតែស្ថិតនៅជាធរមានរហូតទាល់តែមានទិន្នន័យគ្រប់គ្រាន់ ដើម្បីវាយតម្លៃផលប៉ះពាល់ជលផលប្រកបដោយនិរន្តរភាពយូរអង្វែងនៃផលស្តុកទាំងនោះ នៅពេលដែលវិធានការគ្រប់គ្រងនិងអភិរក្សដោយផ្អែកលើការវាយតម្លៃនោះត្រូវបានអនុវត្ត។ ប្រសិនបើសមស្រប វិធានការបន្ទាប់នឹងធ្វើឱ្យមានការរីកចម្រើនធនធានជលផលបន្តិចម្តងៗ។

៧. ប្រសិនបើបាតុភូតធម្មជាតិមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើស្ថានភាពនៃផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ រដ្ឋនានាត្រូវអនុម័តវិធានការគ្រប់គ្រងនិងអភិរក្សជាបន្ទាន់ ដើម្បីធានាថាសកម្មភាពនេសាទទាំងនោះមិនបន្ថែមទម្ងន់ដល់ផលប៉ះពាល់ធ្ងន់ធ្ងរនោះឡើយ។ រដ្ឋនានាត្រូវអនុម័តផងដែរនូវវិធានការគ្រប់គ្រងនិងអភិរក្សជាបន្ទាន់ នៅពេលដែលសកម្មភាពនេសាទបង្ហាញនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់និរន្តរភាពនៃផលស្តុកទាំងនោះ។ វិធានការដែលបានដាក់ចេញជាបន្ទាន់នោះត្រូវតែជាវិធានការបណ្តោះអាសន្ននិងត្រូវផ្អែកលើមូលដ្ឋានភស្តុតាងវិទ្យាសាស្ត្រដ៏ប្រសើរបំផុតដែលមាន។

## មាត្រា៧. ភាពស្របគ្នានៃវិធានការគ្រប់គ្រងនិងអភិរក្ស

១. ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបូរណភាពដែនដីនៃរដ្ឋម្ចាស់ឆ្នេរ ក្នុងគោលបំណងធ្វើអាជីវកម្មនិងស្រាវជ្រាវគ្រប់គ្រង និងអភិរក្សធនធានសមុទ្រមានជីវិតនៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ ដូចដែលបានផ្តល់ក្នុង

អនុសញ្ញា និងសិទ្ធិរបស់រដ្ឋ សម្រាប់ប្រជាជននៃរដ្ឋទាំងនោះ ធ្វើនេសាទនៅសមុទ្រអន្តរជាតិស្របទៅតាមអនុសញ្ញា៖

(ក) ទាក់ទងនឹងផលស្តុកត្រីផ្លាស់ទីមធ្យម រដ្ឋម្ចាស់ឆ្នេរពាក់ព័ន្ធនិងរដ្ឋដែលមានប្រជានេសាទធ្វើនេសាទផលស្តុកត្រីផ្លាស់ទីមធ្យមទាំងនោះ នៅក្នុងតំបន់ជាប់នឹងដែនសមុទ្រអន្តរជាតិ ត្រូវស្វែងរកការឯកភាពលើវិធានការចាំបាច់ សម្រាប់ការអភិរក្សផលស្តុកទាំងនោះក្នុងតំបន់ជាប់សមុទ្រអន្តរជាតិ តាមរយៈយន្តការផ្ទាល់ ឬសមស្របសម្រាប់កិច្ចសហប្រតិបត្តិការ ដូចមានចែងក្នុងផ្នែកទី៣នៃ កិច្ចព្រមព្រៀងនេះ

(ខ) ទាក់ទងទៅនឹងផលស្តុកត្រីផ្លាស់ទីឆ្ងាយ រដ្ឋម្ចាស់ឆ្នេរពាក់ព័ន្ធនិងរដ្ឋដែលមានប្រជានេសាទធ្វើនេសាទផលស្តុកត្រីនៅក្នុងតំបន់ត្រូវសហការ ដើម្បីធានាការអភិរក្ស និងការលើកកម្ពស់ការប្រើប្រាស់ដ៏ប្រសើរបំផុតនូវផលស្តុកទាំងនោះនៅពាសពេញតំបន់ ទាំងនៅក្នុងនិងខាងក្រៅដែនដែលស្ថិតក្រោមយុត្តាធិការជាតិ តាមរយៈយន្តការផ្ទាល់ឬសមស្របសម្រាប់កិច្ចសហប្រតិបត្តិការដូចមានចែងក្នុងផ្នែកទី៣នៃកិច្ចព្រមព្រៀងនេះ។

២. វិធានការគ្រប់គ្រងនិងអភិរក្សដែលបានបង្កើតឡើងសម្រាប់សមុទ្រអន្តរជាតិ និងវិធានការដែលបានអនុម័តសម្រាប់តំបន់នៅក្រោមដែនយុត្តាធិការជាតិត្រូវតែមានភាពស្របគ្នា ដើម្បីធានាការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៅក្នុងស្ថានភាពដើមនិងមិនប្រែប្រួល។ ដើម្បីឈានទៅដល់គោលដៅនេះ រដ្ឋម្ចាស់ឆ្នេរនិងរដ្ឋដែលធ្វើនេសាទនៅក្នុងសមុទ្រអន្តរជាតិ ត្រូវមានកាតព្វកិច្ចធ្វើកិច្ចសហប្រតិបត្តិការ ក្នុងគោលបំណងសម្រេចបាននូវវិធានការស្របគ្នាទាក់ទងនឹងផលស្តុកត្រីទាំងនោះ។ ក្នុងការកំណត់វិធានការគ្រប់គ្រងនិងអភិរក្សស្របគ្នា រដ្ឋនានាត្រូវ៖

(ក) ពិចារណាទៅលើវិធានការគ្រប់គ្រងនិងអភិរក្សដែលអនុម័តនិងអនុវត្តដោយរដ្ឋម្ចាស់ឆ្នេរ ដែលស្ថិតក្រោមដែនយុត្តាធិការជាតិ អនុលោមតាមមាត្រា៦១នៃអនុសញ្ញានេះ ដោយផ្អែកលើផលស្តុកដូចគ្នា និងធានាថាវិធានការទាំងអស់ត្រូវបានបង្កើតឡើងដោយយោងតាមផលស្តុក នៅក្នុងសមុទ្រអន្តរជាតិនឹងមិនធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃវិធានការទាំងនោះ

(ខ) ពិចារណាទៅលើវិធានការដែលបានព្រមព្រៀងគ្នាបង្កើតឡើង និងអនុវត្តកន្លងមកសម្រាប់សមុទ្រអន្តរជាតិដោយរដ្ឋម្ចាស់ឆ្នេរនិងរដ្ឋធ្វើនេសាទនៅសមុទ្រអន្តរជាតិពាក់ព័ន្ធ អនុលោមតាមអនុសញ្ញាដែលមានផលស្តុកដូចគ្នា

(គ) ពិចារណាទៅលើវិធានការដែលបានព្រមព្រៀងគ្នាបង្កើតឡើង និងអនុវត្តកន្លងមកដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬថ្នាក់អនុតំបន់ ឬក្រុមការងារដែលបានរៀបចំឡើងអនុលោមតាមអនុសញ្ញាដែលមានផលស្តុកដូចគ្នា

(ឃ) ពិចារណាទៅលើលក្ខណៈជីវសាស្ត្រផលស្តុកដូចគ្នានិងខុសគ្នា និងទំនាក់ទំនងរវាងរបាយផលស្តុកធនធានជលផល និងលក្ខណៈពិសេសនៃភូមិសាស្ត្រតំបន់ពាក់ព័ន្ធ ដោយគិតទាំងវិសាលភាពផលស្តុកដែលកើតឡើងនិងត្រូវបាននេសាទនៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ

(ង) ពិចារណាទៅលើការពឹងផ្អែកលើផលស្តុកពាក់ព័ន្ធរបស់រដ្ឋម្ចាស់ឆ្នេរ និងរដ្ឋដែលធ្វើនេសាទនៅសមុទ្រអន្តរជាតិ

(ច) ធានាថាវិធានការទាំងនោះមិនបង្កផលប៉ះពាល់ដ៏គ្រោះថ្នាក់ ទៅលើធនធានមានជីវិតទាំងអស់នៅក្នុងសមុទ្រ។

៣. ដោយផ្តល់ប្រសិទ្ធភាពដល់កាតព្វកិច្ចរបស់រដ្ឋក្នុងកិច្ចសហប្រតិបត្តិការ រដ្ឋត្រូវប្រឹងប្រែងដើម្បីឯកភាពលើវិធានការគ្រប់គ្រងនិងអភិរក្សស្របគ្នានៅក្នុងកំលុងពេលសមស្របមួយ។

៤. ប្រសិនបើមិនអាចឈានដល់ការព្រមព្រៀងនៅក្នុងកំលុងពេលសមស្របមួយ រដ្ឋពាក់ព័ន្ធណាក៏ដោយអាចប្រើនីតិវិធីដោះស្រាយទំនាស់ដែលមានចែងក្នុងផ្នែកទី៨។

៥. ក្នុងពេលមិនទាន់មានកិច្ចព្រមព្រៀងស្តីពីវិធានការគ្រប់គ្រងនិងអភិរក្សស្របគ្នា នៅក្នុងស្មារតីនៃការយល់យោគគ្នានិងសហប្រតិបត្តិការ រដ្ឋពាក់ព័ន្ធត្រូវខិតខំប្រឹងប្រែងរៀបចំការអនុវត្តជាក់ស្តែងបណ្តោះអាសន្នមួយ។ ក្នុងលក្ខខណ្ឌដែលរដ្ឋទាំងនោះមិនឯកភាពលើការរៀបចំបែបនេះបាន រដ្ឋពាក់ព័ន្ធណាក៏ដោយអាចដាក់បណ្តឹងជំទាស់ទៅតុលាការឬស្ថាប័នដោះស្រាយទំនាស់ស្របតាមនីតិវិធីដោះស្រាយដែលមានចែងក្នុងផ្នែកទី៨ នៅក្នុងគោលបំណងដើម្បីទទួលបានវិធានការបណ្តោះអាសន្ន។

៦. វិធានការឬការរៀបចំបណ្តោះអាសន្នដែលបានដាក់ចូល ឬបានបញ្ជាក់អនុលោមតាមកថាខណ្ឌទី៥ ត្រូវពិចារណាលើបទប្បញ្ញត្តិនៃផ្នែកនេះ ហើយត្រូវគោរពសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋពាក់ព័ន្ធទាំងអស់ និងមិនត្រូវធ្វើឱ្យប៉ះពាល់ឬរាំងស្ទះដល់ការឈានទៅដល់កិច្ចព្រមព្រៀងចុងក្រោយ លើវិធានការគ្រប់គ្រងនិងអភិរក្សស្របគ្នា ក៏ដូចជាមិនត្រូវធ្វើឱ្យមានព្យសនកម្មលើលទ្ធផលចុងក្រោយ នៃនីតិវិធីដោះស្រាយទំនាស់ណាមួយឡើយ។

៧. រដ្ឋម្ចាស់ឆ្នេរត្រូវផ្តល់ដំណឹងជាប្រចាំដល់រដ្ឋធ្វើនេសាទនៅសមុទ្រអន្តរជាតិ នៅក្នុងតំបន់ ឬអនុតំបន់ដោយផ្ទាល់ឬតាមរយៈអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ឬក្រុមការងារដែលបានរៀបចំឡើងសមស្របណាមួយ ឬតាមរយៈមធ្យោបាយសមស្របដទៃទៀត នៃវិធានការដែលពួកគេបានអនុម័ត សម្រាប់ផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ នៅក្នុងតំបន់ស្ថិតនៅក្រោមដែនយុត្តាធិការជាតិរបស់ប្រទេសគេ។

៨. រដ្ឋដែលធ្វើនេសាទនៅក្នុងសមុទ្រអន្តរជាតិត្រូវជូនដំណឹងជាប្រចាំដល់រដ្ឋដែលពាក់ព័ន្ធដទៃទៀតដោយផ្ទាល់ ឬតាមរយៈអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ ឬក្រុមការងារដែលបានរៀបចំឡើងសមស្របណាមួយ ឬតាមរយៈមធ្យោបាយសមស្របដទៃទៀតនៃវិធានការដែលពួកគេបានអនុម័ត សម្រាប់កំណត់សកម្មភាពនាវាបំពាក់ទង់ជាតិរបស់ពួកគេ ដែលធ្វើនេសាទផលស្តុកទាំងនោះនៅក្នុងសមុទ្រអន្តរជាតិ។

## ផ្នែកទី៣. យន្តការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

### មាត្រា៨. កិច្ចសហប្រតិបត្តិការសម្រាប់ការគ្រប់គ្រងនិងការអភិរក្ស

១. អនុលោមតាមអនុសញ្ញា រដ្ឋម្ចាស់ឆ្នេរនិងរដ្ឋដែលធ្វើនេសាទនៅក្នុងសមុទ្រអន្តរជាតិត្រូវស្វែងរកកិច្ចសហប្រតិបត្តិការទាក់ទងទៅនឹងផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយដោយផ្ទាល់ឬតាមរយៈអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ ឬក្រុមការងារដែលបានរៀបចំឡើងសមស្របណាមួយ ដោយពិចារណាលើលក្ខណៈពិសេសនៃតំបន់ឬអនុតំបន់នោះ ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអភិរក្សផលស្តុកទាំងនោះ។

២. រដ្ឋនានាត្រូវចូលរួមពិគ្រោះយោបល់ប្រកបដោយទំនុកចិត្តខ្ពស់និងគ្មានការពន្យារពេល ជាពិសេសនៅកន្លែងណាដែលមានភស្តុតាងបញ្ជាក់ពីផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយដែលពាក់ព័ន្ធ អាចនឹងស្ថិតនៅក្រោមការគំរាមកំហែងពីការនេសាទហួសកម្រិត ឬការធ្វើនេសាទថ្មីមួយដែលកំពុងធ្វើអាជីវកម្មទៅលើផលស្តុកទាំងនោះ។ ដើម្បីសម្រេចបានគោលដៅនេះ ការពិគ្រោះយោបល់អាចនឹងត្រូវផ្តួចផ្តើមឡើងតាមការស្នើសុំ

របស់រដ្ឋពាក់ព័ន្ធណាមួយដោយយោងតាមគំនិតបង្កើតក្រុមការងារសមស្របដើម្បីធានាការគ្រប់គ្រងនិងអភិរក្សផលស្តុកទាំងនោះ។ ក្នុងពេលមិនទាន់មានកិច្ចព្រមព្រៀងខាងលើ រដ្ឋត្រូវពិនិត្យ បទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ និងត្រូវធ្វើសកម្មភាពប្រកបដោយភាពសុចរិត ដោយគោរពសិទ្ធិ ផលប្រយោជន៍ និងកាតព្វកិច្ចរបស់រដ្ឋដទៃ។

៣. នៅកន្លែងដែលអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ ឬក្រុមការងារដែលបានរៀបចំមានសមត្ថភាពក្នុងការបង្កើតវិធានការគ្រប់គ្រងនិងអភិរក្ស ជាពិសេស សម្រាប់ផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ រដ្ឋធ្វើនេសាទផលស្តុកទាំងនោះនៅក្នុងសមុទ្រអន្តរជាតិនិងរដ្ឋម្ចាស់ឆ្នេរពាក់ព័ន្ធត្រូវផ្តល់សុពលភាពដល់កាតព្វកិច្ចរបស់ខ្លួនក្នុងកិច្ចសហប្រតិបត្តិការ ដើម្បីក្លាយជាសមាជិកនៃអង្គការឬជាអ្នកចូលរួមនៅក្នុងក្រុមការងារនោះ ឬដោយយល់ព្រមអនុវត្តវិធានការគ្រប់គ្រងនិងអភិរក្សដែលបានបង្កើតឡើង។ រដ្ឋដែលទទួលបានផលប្រយោជន៍ពិតប្រាកដពីធនធានជលផលពាក់ព័ន្ធអាចនឹងក្លាយជាសមាជិករបស់អង្គការ ឬជាអ្នកចូលរួមនៅក្នុងក្រុមការងារនោះ។ លក្ខខណ្ឌនៃការចូលរួមនៅក្នុងអង្គការឬក្រុមការងារមិនត្រូវទាត់ចោលនូវសមាជិកភាពឬការចូលរួមរបស់រដ្ឋទាំងនោះឡើយ ហើយលក្ខខណ្ឌទាំងនោះមិនត្រូវបានគេអនុវត្តក្នុងរបៀបរើសអើងចំពោះរដ្ឋណាមួយ ឬរដ្ឋមួយក្រុម ដែលទទួលបានផលប្រយោជន៍ពិតប្រាកដ ពីធនធានជលផលពាក់ព័ន្ធ។

៤. មានតែរដ្ឋដែលជាសមាជិករបស់អង្គការ ឬជាអ្នកចូលរួមនៅក្នុងក្រុមការងារ ឬយល់ព្រមអនុវត្តវិធានការគ្រប់គ្រងនិងអភិរក្សដែលបានបង្កើតឡើងទេ ដែលមានសិទ្ធិប្រើប្រាស់ធនធានជលផល ដោយអនុវត្តតាមវិធានការទាំងនោះ។

៥. នៅកន្លែងដែលគ្មានអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ ឬក្រុមការងារដែលបានរៀបចំបង្កើតវិធានការគ្រប់គ្រងនិងអភិរក្ស ជាពិសេស សម្រាប់ផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ រដ្ឋម្ចាស់ឆ្នេរពាក់ព័ន្ធនិងរដ្ឋធ្វើនេសាទនៅក្នុងសមុទ្រអន្តរជាតិលើផលស្តុកនៅក្នុងតំបន់ឬអនុតំបន់ ត្រូវសហការដើម្បីបង្កើតអង្គការគ្រប់គ្រងជលផលឬចូលរួមក្នុងក្រុមការងារសមស្របដទៃទៀត ដើម្បីធានាពីការគ្រប់គ្រងនិងអភិរក្សផលស្តុកទាំងនោះ និងត្រូវចូលរួមក្នុងការងារនៃអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់។

៦. រដ្ឋណាមួយដែលមានបំណងស្នើឱ្យចាត់វិធានការ ដោយអង្គការអន្តររដ្ឋាភិបាលដែលមានសមត្ថភាពក្នុងកិច្ចការពារធនធានមានជីវិត គួរតែពិគ្រោះយោបល់តាមរយៈអង្គការឬក្រុមការងារជាមួយសមាជិក ឬអ្នកចូលរួម បើសិនជាវិធានការទាំងនោះ អាចនឹងមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់វិធានការគ្រប់គ្រង និងអភិរក្សដែលបានបង្កើតឡើងនោះ។ នៅក្នុងកម្រិតដែលអាចអនុវត្តបាន ការពិគ្រោះយោបល់គួរធ្វើឡើងមុនពេលដាក់សំណើទៅកាន់អង្គការអន្តររដ្ឋាភិបាល។

## មាត្រា៩. អង្គការនិងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់

១. ក្នុងការបង្កើតអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ ឬការចូលរួមក្នុងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់ សម្រាប់ផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ រដ្ឋត្រូវឯកភាពតាមចំណុចដូចខាងក្រោម៖

   (ក) ផលស្តុកដែលត្រូវអនុវត្តតាមវិធានការគ្រប់គ្រងនិងអភិរក្សដោយពិចារណាតាមលក្ខណៈជីវសាស្ត្រផលស្តុកនិងលក្ខណៈជលផលធម្មជាតិដែលពាក់ព័ន្ធ

   (ខ) ចំពោះតំបន់ដែលត្រូវអនុវត្ត ត្រូវពិចារណាតាមមាត្រា៧ កថាខណ្ឌ១នូវលក្ខណៈនៃតំបន់ឬអនុតំបន់ទាំងនោះត្រូវរួមបញ្ចូលទាំងកត្តាសេដ្ឋកិច្ច សង្គម ភូមិសាស្ត្រ និងបរិស្ថាន

(គ) ទំនាក់ទំនងការងាររវាងអង្គការឬក្រុមការងារថ្មី និងតួនាទី គោលបំណង និងប្រតិបត្តិការរបស់អង្គការឬក្រុមការងារគ្រប់គ្រងជលផលពាក់ព័ន្ធដែលមានស្រាប់

(ឃ) យន្តការនៃអង្គការឬក្រុមការងារនឹងទទួលបានដំបូន្មានផ្នែកវិទ្យាសាស្ត្រ និងការពិនិត្យឡើងវិញនូវស្ថានភាពផលស្តុក រួមទាំងការបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយសមស្រប។

២. រដ្ឋដែលសហការក្នុងការបង្កើតអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ត្រូវជូនដំណឹងដល់រដ្ឋផ្សេងទៀតដែលមានបំណងពិតប្រាកដ ចំពោះការចូលរួមក្នុងការងាររបស់អង្គការដែលបានស្នើឡើង ឬការរៀបចំកិច្ចសហប្រតិបត្តិការបែបនោះ។

## មាត្រា១០. ការប្រព្រឹត្តទៅរបស់អង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ និងអនុតំបន់

ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងកិច្ចសហប្រតិបត្តិការតាមរយៈអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ រដ្ឋនានាត្រូវះ

(ក) យល់ព្រមនិងអនុវត្តតាមវិធានការគ្រប់គ្រងនិងអភិរក្ស ដើម្បីធ្វើឱ្យប្រាកដនូវនិរន្តរភាពយូរអង្វែងនៃផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ

(ខ) យល់ព្រមតាមលក្ខខណ្ឌសមស្របណាមួយលើសិទ្ធិចូលរួម ដូចជាការបែងចែកបរិមាណផលនេសាទដែលអនុញ្ញាតឱ្យចាប់ឬកម្រិតនៃសមត្ថភាពនេសាទ

(គ) អនុម័តនិងអនុវត្តតាមបទដ្ឋានអប្បបរមាអន្តរជាតិ ដែលត្រូវបានណែនាំជាទូទៅសម្រាប់កិច្ចប្រតិបត្តិការនេសាទដោយការទទួលខុសត្រូវ

(ឃ) ទទួលបាននិងវាយតម្លៃដំបូន្មានវិទ្យាសាស្ត្រ ព្រមទាំងពិនិត្យឡើងវិញពីស្ថានភាពផលស្តុក ក៏ដូចជាការវាយតម្លៃពីផលប៉ះពាល់នៃការនេសាទលើប្រភេទត្រីមិនមែនគោលដៅ និងប្រភេទត្រីពាក់ព័ន្ធឬប្រភេទត្រីពឹងអាស្រ័យ

(ង) យល់ព្រមលើបទដ្ឋានសម្រាប់ការប្រមូល ការរាយការណ៍ ការផ្ទៀងផ្ទាត់ និងការផ្លាស់ប្តូរ ទិន្នន័យស្ដីពីជលផលសម្រាប់ផលស្តុកទាំងនោះ

(ច) ចងក្រងនិងចែកចាយទិន្នន័យស្ថិតិពេញលេញនិងត្រឹមត្រូវដូចដែលបានពិពណ៌នាក្នុង**ឧបសម្ព័ន្ធ១** ដើម្បីធ្វើឱ្យប្រាកដថាភស្តុតាងវិទ្យាសាស្ត្រដ៏ល្អបំផុតអាចរកបាននិងរក្សាការសម្ងាត់ទៅតាមការជាក់ស្តែង

(ឆ) ជំរុញនិងធ្វើការវាយតម្លៃវិទ្យាសាស្ត្រលើផលស្តុកនិងការសិក្សាស្រាវជ្រាវពាក់ព័ន្ធ ហើយចែកចាយលទ្ធផលដែលរកឃើញ

(ជ) បង្កើតយន្តការសហប្រតិបត្តិការសមស្របសម្រាប់ការតាមដាន ការត្រួតពិនិត្យ ការអង្កេត និងការបង្ក្រាប ប្រកបដោយប្រសិទ្ធភាព

(ឈ) យល់ស្របលើមធ្យោបាយដែលធ្វើឱ្យផលប្រយោជន៍ ពីការនេសាទរបស់សមាជិកថ្មីនៃអង្គការ ឬអ្នកចូលរួមថ្មីនៅក្នុងក្រុមការងារនេះនឹងត្រូវបានរៀបចំសម្របសម្រួល

(ញ) យល់ព្រមលើដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដែលសម្របសម្រួលការអនុម័តវិធានការគ្រប់គ្រងនិងអភិរក្សប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា

(ដ) លើកកម្ពស់ការដោះស្រាយទំនាស់ដោយសន្តិវិធីស្របតាមផ្នែកទី៨

(ថ) ធានាថាមានកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញពីទីភ្នាក់ងារជាតិនិងភ្នាក់ងារឧស្សាហកម្មពាក់ព័ន្ធរបស់រដ្ឋក្នុងការអនុវត្តអនុសាសន៍និងសេចក្តីសម្រេចចិត្តរបស់អង្គការឬក្រុមការងារ

(ទ) ផ្តល់ជូនជាសាធារណៈនូវសកម្មភាពនៃការគ្រប់គ្រង និងអភិរក្សដែលបង្កើតឡើងដោយអង្គការ ឬក្រុមការងារ។

## មាត្រា១១. សមាជិកឬអ្នកចូលរួមថ្មី

ការកំណត់លក្ខណៈ និងវិសាលភាពនៃសិទ្ធិចូលរួមសម្រាប់សមាជិកថ្មី របស់អង្គការគ្រប់គ្រប់ជលផលថ្នាក់តំបន់ឬអនុតំបន់មួយ ឬសម្រាប់អ្នកចូលរួមថ្មីនៅក្នុងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់មួយ រដ្ឋនានាត្រូវពិចារណាទៅលើចំណុចដូចខាងក្រោម៖

(ក) ស្ថានភាពនៃផលស្តុកត្រីផ្លាស់ទីមធ្យម ឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ និងកម្រិតសមត្ថភាពនេសាទដែលកំពុងអនុវត្ត

(ខ) ផលប្រយោជន៍រៀងខ្លួន ទម្រង់នៃការនេសាទ និងការនេសាទរបស់សមាជិកឬអ្នកចូលរួមចាស់ និងថ្មី

(គ) ការចូលរួមចំណែករបស់សមាជិកនិងអ្នកចូលរួមចាស់និងថ្មីក្នុងការគ្រប់គ្រងនិងអភិរក្សផលស្តុក ការប្រមូល និងផ្តល់ទិន្នន័យត្រឹមត្រូវ និងសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រលើផលស្តុកទាំងនោះ

(ឃ) សេចក្តីត្រូវការរបស់សហគមន៍នេសាទនៅតំបន់ឆ្នេរ ដែលពឹងអាស្រ័យជាចម្បងលើការនេសាទលើផលស្តុកទាំងនោះ

(ង) សេចក្តីត្រូវការរបស់រដ្ឋម្ចាស់ឆ្នេរដែលសេដ្ឋកិច្ចរបស់រដ្ឋទាំងនោះពឹងផ្អែកលើសលុប លើការធ្វើអាជីវកម្មធនធានសមុទ្រមានជីវិត

(ច) ផលប្រយោជន៍ប្រទេសកំពុងអភិវឌ្ឍពីតំបន់ ឬអនុតំបន់ដែលផលស្តុកទាំងនោះស្ថិតនៅក្នុងតំបន់ដែនយុត្តាធិការជាតិនៃរដ្ឋទាំងនោះ។

## មាត្រា១២. តម្លាភាពនៅក្នុងសកម្មភាពរបស់អង្គការនិងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់

១. រដ្ឋនានាត្រូវមានតម្លាភាពក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនិងសកម្មភាពដទៃទៀតរបស់អង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់។

២. តំណាងពីស្ថាប័នអន្តររដ្ឋាភិបាល និងតំណាងពីអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ដែលពាក់ព័ន្ធនឹងផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ត្រូវទទួលបានឱកាសចូលរួមកិច្ចប្រជុំអង្គការ និងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់ ក្នុងនាមជាអ្នកសង្កេតការណ៍ ឬម្យ៉ាងវិញទៀត តំណាងទាំងនោះអាចចូលរួមក្នុងកិច្ចប្រជុំស្របតាមនីតិវិធីរបស់អង្គការឬក្រុមការងារពាក់ព័ន្ធ។ នីតិវិធីទាំងនោះមិនអាចតឹងតែងហួសហេតុពេកទេ។ ស្ថាប័នអន្តររដ្ឋាភិបាលនិងតំណាងអង្គការមិនមែនរដ្ឋាភិបាលទាំងនោះអាចប្រើប្រាស់កំណត់ត្រានិងរបាយការណ៍របស់អង្គការ ឬក្រុមការងារទាំងនោះឱ្យទាន់ពេលវេលាតាមនីតិវិធីស្តីពីការប្រើកំណត់ត្រានិងរបាយការណ៍នោះ។

## មាត្រា១៣. ការពង្រឹងអង្គការនិងក្រុមការងារដែលមានស្រាប់

រដ្ឋនានាត្រូវសហការគ្នាដើម្បីពង្រឹងអង្គការ និងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ និងអនុតំបន់ដែលមានស្រាប់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃស្ថាប័នទាំងនោះក្នុងការបង្កើតនិងអនុវត្ត វិធានការគ្រប់គ្រងនិងអភិរក្សលើផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

## មាត្រា១៤.ការប្រមូលនិងផ្តល់ព័ត៌មាន និងកិច្ចសហប្រតិបត្តិការ ក្នុងការសិក្សាស្រាវជ្រាវវិទ្យា សាស្ត្រ

១. រដ្ឋនានាត្រូវធានាថា នាវានេសាទដែលបំពាក់ទង់ជាតិរបស់រដ្ឋខ្លួនត្រូវផ្តល់ព័ត៌មានចាំបាច់សម្រាប់ការបំពេញកាតព្វកិច្ចរបស់នាវាដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ។ ដើម្បីសម្រេចបានកិច្ចការនេះ រដ្ឋនានាត្រូវធ្វើឱ្យស្របតាម**ឧបសម្ព័ន្ធ១**៖
   - (ក) ប្រមូលនិងផ្លាស់ប្តូរទិន្នន័យស្ថិតិ បច្ចេកទេស និងវិទ្យាសាស្ត្រទាក់ទងទៅនឹងផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ
   - (ខ) ធានាថាទិន្នន័យទាំងនោះត្រូវបានប្រមូលដោយលម្អិត គ្រប់គ្រាន់ ដើម្បីសម្របសម្រួលដល់ការវាយតម្លៃផលស្តុកប្រកបដោយប្រសិទ្ធភាព និងត្រូវផ្តល់របាយការណ៍វាយតម្លៃផលស្តុកនោះឱ្យទាន់ពេលវេលាដើម្បីបំពេញតម្រូវការរបស់អង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់
   - (គ) ចាត់វិធានការសមស្របដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃទិន្នន័យនោះ។

២. រដ្ឋនានាត្រូវសហការដោយផ្ទាល់ឬតាមរយៈអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ដើម្បី៖
   - (ក) យល់ព្រមទៅលើទម្រង់និងទិន្នន័យជាក់លាក់ ដែលត្រូវផ្តល់ឱ្យអង្គការឬក្រុមការងារទាំងនោះ ដោយពិចារណាពីលក្ខណៈធម្មជាតិរបស់ផលស្តុកនិងការនេសាទពីផលស្តុកទាំងអស់
   - (ខ) អភិវឌ្ឍនិងចែករំលែកបច្ចេកទេសវិភាគ និងវិធីសាស្ត្រវាយតម្លៃផលស្តុក ក្នុងការធ្វើឱ្យប្រសើរឡើងនូវវិធានការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

៣. ស្របនឹងផ្នែកទី៨នៃអនុសញ្ញា រដ្ឋនានាត្រូវសហការគ្នាដោយផ្ទាល់ឬតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ចដើម្បីពង្រឹងសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រវិស័យជលផល ព្រមទាំងជំរុញការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រទាក់ទងនឹងការគ្រប់គ្រង និងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម ឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ ដើម្បីផលប្រយោជន៍ទាំងអស់គ្នា។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋឬអង្គការអន្តរជាតិ ដែលមានសមត្ថកិច្ចធ្វើការសិក្សានៅក្រៅតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ ត្រូវជំរុញការបោះពុម្ពនិងផ្សព្វផ្សាយឱ្យបានសកម្មដល់រដ្ឋពាក់ព័ន្ធពីលទ្ធផលនិងព័ត៌មាននៃការសិក្សាស្រាវជ្រាវនោះ ដោយមានទំនាក់ទំនងជាមួយគោលបំណងនិងវិធីសាស្ត្រ។ រដ្ឋនានាត្រូវសម្របសម្រួលដល់ការចូលរួមរបស់អ្នកវិទ្យាសាស្ត្រមកពីរដ្ឋទាំងនោះ ក្នុងការចូលរួមសិក្សាស្រាវជ្រាវទៅតាមលទ្ធភាពដែលអាចធ្វើបាន។

## មាត្រា១៥. សមុទ្រក្នុងនិងឈូងសមុទ្រ

នៅក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ រដ្ឋនានាត្រូវពិចារណាដល់លក្ខណៈធម្មជាតិនៅក្នុងសមុទ្រក្នុង និងឈូងសមុទ្រ និងត្រូវធ្វើសកម្មភាពឱ្យស្របនឹង**ផ្នែកទី៩** និងមាត្រាពាក់ព័ន្ធដទៃទៀតនៃអនុសញ្ញា។

## មាត្រា១៦.តំបន់សមុទ្រអន្តរជាតិព័ទ្ធជុំវិញទាំងស្រុងដោយតំបន់សមុទ្រស្ថិតនៅក្រោមដែនយុត្តាធិការនៃរដ្ឋទោលមួយ

១. រដ្ឋនានាដែលនេសាទផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ នៅដែនសមុទ្រអន្តរជាតិដែលព័ទ្ធជុំវិញទាំងស្រុង ដោយតំបន់សមុទ្រស្ថិតនៅក្រោមយុត្តាធិការនៃរដ្ឋទោលមួយ ហើយរដ្ឋទោលនោះត្រូវ សហការដើម្បីបង្កើតវិធានការគ្រប់គ្រង និងអភិរក្សផលស្តុកទាំងនោះ នៅក្នុងតំបន់ដែនសមុទ្រអន្តរជាតិ។ យោងទៅលើលក្ខណៈធម្មជាតិនៃតំបន់នោះ រដ្ឋនានាត្រូវយកចិត្តទុកដាក់ជាពិសេសដើម្បីបង្កើតវិធានការគ្រប់គ្រងនិងអភិរក្សសមស្របមួយសម្រាប់ផលស្តុកទាំងនោះស្របតាមមាត្រា៧។ វិធានការដែលធ្វើឡើងទាក់ទងនឹងដែនសមុទ្រអន្តរជាតិត្រូវពិចារណាដល់សិទ្ធិ កាតព្វកិច្ច និងផលប្រយោជន៍របស់រដ្ឋម្ចាស់ឆ្នេរដែលស្ថិតនៅក្រោមអនុសញ្ញា ដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រល្អបំផុតដែលអាចរកបាន ហើយរដ្ឋត្រូវពិចារណាផងដែរទៅដល់វិធានការគ្រប់គ្រង និងអភិរក្សដែលបានអនុម័ត និងបានអនុវត្តដោយរដ្ឋម្ចាស់ឆ្នេរនៅក្នុងតំបន់ស្ថិតនៅក្រោមដែនយុត្តាធិការជាតិ ចំពោះផលស្តុករួមគ្នា ដោយអនុលោមតាមមាត្រា៦១នៃ អនុសញ្ញា។ រដ្ឋនានាក៏ត្រូវយល់ព្រមផងដែរទៅលើវិធានការសម្រាប់ការតាមដាន ត្រួតពិនិត្យ អង្កេត និងការបង្ក្រាបដើម្បីធានាថាវិធានការគ្រប់គ្រងនិងអភិរក្សពាក់ព័ន្ធនឹងដែនសមុទ្រអន្តរជាតិត្រូវបានអនុវត្ត។

២. ស្របតាមមាត្រា៨ រដ្ឋនានាត្រូវធ្វើសកម្មភាពដោយសុចរិតនិងខិតខំប្រឹងប្រែងដើម្បីយល់ព្រមឱ្យទាន់ពេលវេលាលើវិធានការគ្រប់គ្រងនិងអភិរក្ស ដើម្បីអនុវត្តការធ្វើអាជីវកម្មនេសាទក្នុងតំបន់ដែលមានចែងក្នុងកថាខណ្ឌទី១។ ប្រសិនបើក្នុងកំលុងពេលសមស្របណាមួយ រដ្ឋធ្វើនេសាទពាក់ព័ន្ធនិងរដ្ឋម្ចាស់ឆ្នេរមិនយល់ព្រមលើវិធានការទាំងនោះទេ ពួកគេត្រូវអនុលោមតាមកថាខណ្ឌទី១នៃមាត្រា១៦ និងអនុវត្តតាមកថាខណ្ឌទី៤ កថាខណ្ឌទី៥ និងកថាខណ្ឌទី៦នៃមាត្រា៧ ទាក់ទងនឹងវិធានការឬការរៀបចំបណ្តោះអាសន្ន។ ក្នុងពេលដែលមិនទាន់បានបង្កើតវិធានការឬការរៀបចំបណ្តោះអាសន្នទាំងនោះ រដ្ឋពាក់ព័ន្ធត្រូវចាត់វិធានការទៅលើនាវាដែលប្រើប្រាស់ទង់ជាតិរបស់ខ្លួន ដើម្បីធានាថានាវាទាំងនោះមិនពាក់ព័ន្ធនឹងការនេសាទដែលធ្វើឱ្យអន្តរាយដល់ផលស្តុក។

# ផ្នែកទី៤.រដ្ឋមិនមែនជាសមាជិកនិងរដ្ឋមិនមែនជាអ្នកចូលរួម

## មាត្រា១៧.រដ្ឋមិនមែនជាសមាជិករបស់អង្គការនិងរដ្ឋមិនមែនជាអ្នកចូលរួមនៅក្នុងក្រុមការងារ

១. រដ្ឋដែលមិនមែនជាសមាជិករបស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ ឬក៏មិនមែនជារដ្ឋចូលរួមក្នុងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ និងទោះបីជាមិនឯកភាពអនុវត្តវិធានការគ្រប់គ្រងនិងអភិរក្សដែលបានបង្កើតឡើងដោយអង្គការឬក្រុមការងារនោះក៏ដោយ ក៏មិនត្រូវបានចាត់ទុកថាមិនមានកាតព្វកិច្ចក្នុងការសហការក្នុងការគ្រប់គ្រង និងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម ឬផលស្តុកត្រីផ្លាស់ទីឆ្ងាយដោយអនុលោមតាមអនុសញ្ញានិងកិច្ចព្រមព្រៀងនេះ។

២. រដ្ឋនោះមិនត្រូវអនុញ្ញាតឱ្យនាវាបំពាក់ទង់ជាតិរបស់ខ្លួនធ្វើនេសាទផលស្តុកត្រីផ្លាស់ទីមធ្យម ឬផលស្តុកត្រីផ្លាស់ទីឆ្ងាយដែលស្ថិតនៅក្រោមវិធានការគ្រប់គ្រងនិងអភិរក្សដែលបានបង្កើតឡើងដោយអង្គការឬក្រុមការងារនោះ។

៣. រដ្ឋដែលជាសមាជិករបស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ ឬជារដ្ឋដែលចូលរួមជាមួយក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ ឬអនុតំបន់ ត្រូវស្នើសុំជាលក្ខណៈឯកតោភាគីឬពហុភាគីទៅកាន់អង្គភាពនេសាទ ដូចដែលមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា១ ចំពោះនាវាដែលធ្វើនេសាទក្នុងតំបន់ពាក់ព័ន្ធដើម្បីសហការឱ្យបានពេញលេញជាមួយអង្គការ ឬក្រុមការងារនោះ ហើយរដ្ឋទាំងនោះត្រូវអនុវត្តវិធានការគ្រប់គ្រងនិងអភិរក្សដែលបានបង្កើតជាទស្សនៈឱ្យមានការអនុវត្តជាក់ស្តែង នូវវិធានការទាំងនោះឱ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន។ អង្គភាពនេសាទទាំងនោះនឹងទទួលបានផលប្រយោជន៍ពីការចូលរួមធ្វើនេសាទស្របតាមការប្តេជ្ញាចិត្តរបស់រដ្ឋទាំងនោះ ដោយគោរពតាមវិធានការគ្រប់គ្រងនិងអភិរក្សទាក់ទងនឹងផលស្តុក។

៤. រដ្ឋដែលជាសមាជិកនៃអង្គការឬជារដ្ឋចូលរួមនៅក្នុងក្រុមការងារ ត្រូវផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងសកម្មភាពនាវានេសាទដែលបំពាក់ទង់ជាតិរបស់រដ្ឋដែលមិនមែនជាសមាជិករបស់អង្គការឬជារដ្ឋមិនចូល រួមនៅក្នុងក្រុមការងារនោះ ហើយដែលចូលក្នុងប្រតិបត្តិការនេសាទពីផលស្តុកពាក់ព័ន្ធទាំងនោះ។ រដ្ឋទាំងនោះត្រូវចាត់វិធានការឱ្យស្របតាមកិច្ចព្រមព្រៀងនិងច្បាប់អន្តរជាតិ ដើម្បីទប់ស្កាត់សកម្មភាពនាវាទាំងឡាយណាដែលមិនបានពិចារណាលើប្រសិទ្ធភាពនៃវិធានការគ្រប់គ្រងនិងអភិរក្សនៅថ្នាក់តំបន់ឬអនុតំបន់។

## ផ្នែកទី៥. ភាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ

### មាត្រា១៨. ភាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ

១. រដ្ឋដែលនាវានេសាទរបស់ខ្លួនធ្វើនេសាទនៅដែនសមុទ្រអន្តរជាតិ ត្រូវចាត់វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រាកដថា នាវាដែលប្រើប្រាស់ទង់ជាតិរបស់ខ្លួនអនុវត្តតាមវិធានការអភិរក្ស និងគ្រប់គ្រងថ្នាក់តំបន់ និងអនុតំបន់ ហើយមិនត្រូវធ្វើសកម្មភាពណាមួយដែលមិនបានពិចារណាពីប្រសិទ្ធភាពនៃវិធានការទាំងនោះ។

២. រដ្ឋត្រូវអនុញ្ញាតឱ្យនាវាដែលបំពាក់ទង់ជាតិរបស់ខ្លួនធ្វើនេសាទនៅសមុទ្រអន្តរជាតិ នៅកន្លែងណាដែលរដ្ឋខ្លួនអាចអនុវត្តការទទួលខុសត្រូវរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពពាក់ព័ន្ធនឹងនាវាដែលស្ថិតនៅក្រោម អនុសញ្ញា និងកិច្ចព្រមព្រៀងនេះ។

៣. វិធានការដែលនឹងត្រូវយកមកអនុវត្តដោយរដ្ឋពាក់ព័ន្ធនឹងនាវាដែលបំពាក់ទង់ជាតិរបស់ខ្លួនមានដូចខាងក្រោម៖

(ក) គ្រប់គ្រងនាវានៅសមុទ្រអន្តរជាតិតាមរយៈមធ្យោបាយនៃការផ្តល់អាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការ ឬលិខិតអនុញ្ញាត ដោយផ្អែកលើនីតិវិធីដែលអនុវត្ត តាមការព្រមព្រៀងនៅថ្នាក់តំបន់ ឬអនុតំបន់ ឬពិភពលោក

(ខ) ការបង្កើតបទបញ្ជា៖

(i) ដើម្បីអនុវត្តលក្ខខណ្ឌនិងសុពលភាពនៃអាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការឬលិខិតអនុញ្ញាត ដើម្បីបំពេញកាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ ឱ្យពេញលេញនៅថ្នាក់តំបន់ ឬ អនុតំបន់ ឬពិភពលោក

(ii) ហាមឃាត់ការនេសាទនៅសមុទ្រអន្តរជាតិចំពោះនាវាដែលគ្មានអាជ្ញាបណ្ណនេសាទ ឬការអនុញ្ញាតជាផ្លូវការ ឬលិខិតអនុញ្ញាតដើម្បីនេសាទ ឬការនេសាទនៅដែនសមុទ្រអន្តរជាតិ ដោយនាវាដែលប្រព្រឹត្តផ្ទុយពីលក្ខខណ្ឌនិងសុពលភាពនៃអាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការឬលិខិតអនុញ្ញាត

(iii) តម្រូវឱ្យនាវាដែលធ្វើនេសាទនៅសមុទ្រអន្តរជាតិយកអាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការ ឬលិខិតអនុញ្ញាត តាមនាវាគ្រប់ពេលវេលា ដើម្បីបង្ហាញមន្ត្រីមានសមត្ថកិច្ចនៅពេលធ្វើអធិការកិច្ច

(iv) ដើម្បីធានាថានាវាដែលបំពាក់ទង់ជាតិរបស់រដ្ឋខ្លួនមិននេសាទ ដោយគ្មានការអនុញ្ញាតនៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិរបស់រដ្ឋដទៃ។

(គ) ការបង្កើតកំណត់ត្រាជាតិមួយស្តីពីនាវានេសាទ ដែលត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទ នៅសមុទ្រអន្តរជាតិ និងអាចយកប្រើបាន នូវព័ត៌មានដែលមាននៅក្នុងកំណត់ត្រាទាំងនោះ តាមការស្នើសុំដោយរដ្ឋពាក់ព័ន្ធ ស្របតាមច្បាប់ជាតិនៃរដ្ឋម្ចាស់ទង់ជាតិ ទាក់ទងទៅនឹងការបញ្ចេញព័ត៌មាននោះ

៤. រដ្ឋដែលជាសមាជិកនៃអង្គការឬជារដ្ឋចូលរួមនៅក្នុងក្រុមការងារ ត្រូវផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងសកម្មភាពនាវានេសាទដែលបំពាក់ទង់ជាតិរបស់រដ្ឋដែលមិនមែនជាសមាជិករបស់អង្គការឬជារដ្ឋមិនចូល រួមនៅក្នុងក្រុមការងារនោះ ហើយដែលចូលក្នុងប្រតិបត្តិការនេសាទពីផលស្តុកពាក់ព័ន្ធទាំងនោះ។ រដ្ឋទាំងនោះត្រូវចាត់វិធានការឱ្យស្របតាមកិច្ចព្រមព្រៀងនិងច្បាប់អន្តរជាតិ ដើម្បីទប់ស្កាត់សកម្មភាពនាវាទាំងឡាយណាដែលមិនបានពិចារណាលើប្រសិទ្ធភាពនៃវិធានការគ្រប់គ្រងនិងអភិរក្សនៅថ្នាក់តំបន់ឬអនុតំបន់។

## ផ្នែកទី៥. ភាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ

### មាត្រា១៨. ភាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ

១. រដ្ឋដែលនាវានេសាទរបស់ខ្លួនធ្វើនេសាទនៅដែនសមុទ្រអន្តរជាតិ ត្រូវចាត់វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រាកដថា នាវាដែលប្រើប្រាស់ទង់ជាតិរបស់ខ្លួនអនុវត្តតាមវិធានការអភិរក្ស និងគ្រប់គ្រងថ្នាក់តំបន់ និងអនុតំបន់ ហើយមិនត្រូវធ្វើសកម្មភាពណាមួយដែលមិនបានពិចារណាពីប្រសិទ្ធភាពនៃវិធានការទាំងនោះ។

២. រដ្ឋត្រូវអនុញ្ញាតឱ្យនាវាដែលបំពាក់ទង់ជាតិរបស់ខ្លួនធ្វើនេសាទនៅសមុទ្រអន្តរជាតិ នៅកន្លែងណាដែលរដ្ឋខ្លួនអាចអនុវត្តការទទួលខុសត្រូវរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពពាក់ព័ន្ធនឹងនាវាដែលស្ថិតនៅក្រោម អនុសញ្ញា និងកិច្ចព្រមព្រៀងនេះ។

៣. វិធានការដែលនឹងត្រូវយកមកអនុវត្តដោយរដ្ឋពាក់ព័ន្ធនឹងនាវាដែលបំពាក់ទង់ជាតិរបស់ខ្លួនមានដូចខាងក្រោម៖

(ក) គ្រប់គ្រងនាវានៅសមុទ្រអន្តរជាតិតាមរយៈមធ្យោបាយនៃការផ្តល់អាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការ ឬលិខិតអនុញ្ញាត ដោយផ្អែកលើនីតិវិធីដែលអនុវត្ត តាមការព្រមព្រៀងនៅថ្នាក់តំបន់ ឬអនុតំបន់ ឬពិភពលោក

(ខ) ការបង្កើតបទបញ្ជា៖

(i) ដើម្បីអនុវត្តលក្ខខណ្ឌនិងសុពលភាពនៃអាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការឬលិខិតអនុញ្ញាត ដើម្បីបំពេញកាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ ឱ្យពេញលេញនៅថ្នាក់តំបន់ ឬ អនុតំបន់ ឬពិភពលោក

(ii) ហាមឃាត់ការនេសាទនៅសមុទ្រអន្តរជាតិចំពោះនាវាដែលគ្មានអាជ្ញាបណ្ណនេសាទ ឬការអនុញ្ញាតជាផ្លូវការ ឬលិខិតអនុញ្ញាតដើម្បីនេសាទ ឬការនេសាទនៅដែនសមុទ្រអន្តរជាតិ ដោយនាវាដែលប្រព្រឹត្តផ្ទុយពីលក្ខខណ្ឌនិងសុពលភាពនៃអាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការឬលិខិតអនុញ្ញាត

(iii) តម្រូវឱ្យនាវាដែលធ្វើនេសាទនៅសមុទ្រអន្តរជាតិយកអាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការ ឬលិខិតអនុញ្ញាត តាមនាវាគ្រប់ពេលវេលា ដើម្បីបង្ហាញមន្ត្រីមានសមត្ថកិច្ចនៅពេលធ្វើអធិការកិច្ច

(iv) ដើម្បីធានាថានាវាដែលបំពាក់ទង់ជាតិរបស់រដ្ឋខ្លួនមិននេសាទ ដោយគ្មានការអនុញ្ញាតនៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិរបស់រដ្ឋដទៃ។

(គ) ការបង្កើតកំណត់ត្រាជាតិមួយស្តីពីនាវានេសាទ ដែលត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទ នៅសមុទ្រអន្តរជាតិ និងអាចយកប្រើបាន នូវព័ត៌មានដែលមាននៅក្នុងកំណត់ត្រាទាំងនោះ តាមការស្នើសុំដោយរដ្ឋពាក់ព័ន្ធ ស្របតាមច្បាប់ជាតិនៃរដ្ឋម្ចាស់ទង់ជាតិ ទាក់ទងទៅនឹងការបញ្ចេញព័ត៌មាននោះ

(ឃ) ត្រូវធ្វើកំណត់សម្គាល់នាវា និងឧបករណ៍នេសាទសម្រាប់កំណត់អត្តសញ្ញាណស្របតាមបទដ្ឋាននាវាដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ នូវប្រព័ន្ធកំណត់សម្គាល់ឧបករណ៍និងនាវានេសាទដូចជាបទដ្ឋានដែលបានកំណត់ដោយអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ

(ង) តម្រូវការក្នុងការកត់ត្រានិងរាយការណ៍ឱ្យទាន់ពេលវេលាពីទីតាំងនាវា ផលនេសាទនៃប្រភេទគោលដៅនិងមិនមែនគោលដៅ សមត្ថភាពនេសាទ និងទិន្នន័យផលផលពាក់ព័ន្ធដទៃទៀត ស្របទៅតាមបទដ្ឋានស្តង់ដារថ្នាក់តំបន់ ឬអនុតំបន់ ឬសកលលោក ក្នុងការប្រមូលទិន្នន័យ

(ច) តម្រូវការក្នុងការផ្ទៀងផ្ទាត់ប្រភេទផលនេសាទនៃប្រភេទគោលដៅនិងមិនមែនគោលដៅ តាមរយៈកម្មវិធីសង្កេតការ បទដ្ឋានអធិការកិច្ច របាយការណ៍ឡើងផលនេសាទ ការណែនាំក្នុងការផ្ទេរផលនេសាទ និងការតាមដានការឡើងផលនេសាទ និងស្ថិតិទីផ្សារ

(ជ) ការអង្កេត តាមដាន និងត្រួតពិនិត្យនាវា ប្រតិបត្តិការនេសាទ និងសកម្មភាពពាក់ព័ន្ធរបស់នាវាទាំងនោះដូចខាងក្រោម៖

(i) ការអនុវត្តតាមបទដ្ឋានអធិការកិច្ចរបស់ជាតិនិងបទដ្ឋានថ្នាក់តំបន់ និងអនុតំបន់សម្រាប់កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ស្របតាមមាត្រា២១និងមាត្រា២២ រួមមានដូចជា ការតម្រូវឱ្យនាវាទាំងនោះអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចដែលទទួលបានការអនុញ្ញាតត្រឹមត្រូវពីរដ្ឋដទៃទៀត អាចចូលទៅធ្វើអធិការកិច្ចបាន

(ii) ការអនុវត្តកម្មវិធីសង្កេតការណ៍ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អនុតំបន់ដែលនៅក្នុងនោះ រដ្ឋម្ចាស់ទង់ជាតិជាអ្នកចូលរួមជាមួយ រួមទាំងការតម្រូវឱ្យនាវាទាំងនោះអនុញ្ញាតឱ្យមន្ត្រីសង្កេតការណ៍ពីរដ្ឋដទៃអាចចូលទៅធ្វើការស្របតាមមុខងារដែលបានព្រមព្រៀងគ្នា ក្រោមលក្ខខណ្ឌកម្មវិធីទាំងនោះ

(iii) ការអភិវឌ្ឍនិងអនុវត្តប្រព័ន្ធតាមដាននាវា មានដូចជាប្រព័ន្ធបញ្ជូនព័ត៌មានតាមផ្កាយរណបពីនាវាឱ្យសមស្របតាមអ្វីដែលអាចធ្វើបាន ដោយប្រព័ន្ធទាំងនោះស្របតាមកម្មវិធីជាតិ និងទទួលបានការយល់ព្រមពីបណ្តារដ្ឋពាក់ព័ន្ធទាំងថ្នាក់តំបន់ ឬអនុតំបន់ ឬសកលលោក។

(ឈ) បទប្បញ្ញត្តិនៃការផ្ទេរផលនេសាទនៅសមុទ្រអន្តរជាតិ ដើម្បីធានាថាវិធានការគ្រប់គ្រង និងអភិរក្សប្រកបប្រសិទ្ធភាពមិនត្រូវបានរាំងស្ទះ

(ញ) បទប្បញ្ញត្តិនៃសកម្មភាពនេសាទដើម្បីធានាដល់ការអនុវត្តតាមវិធានការថ្នាក់តំបន់ ឬអនុតំបន់ ឬសកលលោក ដោយរាប់បញ្ចូលទាំងវិធានការទាំងនោះ ដែលមានគោលបំណងកំណត់ប្រភេទផលនេសាទមិនមែនគោលដៅនៃការនេសាទក្នុងកម្រិតអប្បបរមា។

៤. រដ្ឋត្រូវតែធានាថាវិធានការដែលបានដាក់ទៅលើនាវាដែលបំពាក់ទង់ជាតិរបស់ខ្លួនអាចមានលក្ខណៈសមស្របនឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងអង្កេត ដែលទទួលបានការយល់ព្រមនៅថ្នាក់តំបន់ ឬអនុតំបន់ ឬសកលលោកដែលចូលជាធរមាន។

## ផ្នែកទី៦. ការគោរពនិងការអនុវត្តច្បាប់

### មាត្រា១៩. ការគោរពនិងការអនុវត្តច្បាប់ដោយរដ្ឋម្ចាស់ទង់ជាតិ

១. រដ្ឋមួយត្រូវធានានូវការគោរពច្បាប់របស់នាវាដែលបំពាក់ទង់ជាតិខ្លួន ទៅតាមវិធានការគ្រប់គ្រងនិងអភិរក្សថ្នាក់តំបន់ និងអនុតំបន់សម្រាប់ផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ។ ដើម្បីសម្រេចកិច្ចការនេះ រដ្ឋនោះត្រូវ៖

(ក) ពង្រឹងការអនុវត្តវិធានការទាំងនោះដោយមិនគិតពីទីកន្លែងដែលមានការបំពានកើតឡើង
(ខ) ស៊ើបអង្កេតជាបន្ទាន់ និងពេញលេញ នូវការចោទប្រកាន់បទល្មើសណាមួយ ទៅលើវិធានការគ្រប់គ្រង និងអភិរក្សថ្នាក់តំបន់ ឬអនុតំបន់ដែលអាចរាប់បញ្ចូលទាំងអធិការកិច្ចនៅលើនាវា ពាក់ព័ន្ធដោយផ្ទាល់ និងរាយការណ៍ជាបន្ទាន់ទៅរដ្ឋដែលចោទប្រកាន់លើការរំលោភបំពាន ឬទៅអង្គការ ឬទៅក្រុមការងារពាក់ព័ន្ធថ្នាក់តំបន់ឬអនុតំបន់ ស្តីពីវឌ្ឍនភាពនិងលទ្ធផលនៃការស៊ើបអង្កេត
(គ) តម្រូវឱ្យនាវាណាមួយដែលបំពាក់ទង់ជាតិរបស់រដ្ឋខ្លួន ផ្តល់ព័ត៌មានទៅកាន់អាជ្ញាធរស៊ើបអង្កេតទាក់ទងនឹងទីតាំងនាវា ផលនេសាទ ឧបករណ៍នេសាទ ប្រតិបត្តិការនេសាទ និងសកម្មភាពពាក់ព័ន្ធនៅក្នុងតំបន់ដែលការរំលោភបំពានត្រូវបានចោទប្រកាន់
(ឃ) ប្រសិនបើប្រាកដថាមានភស្តុតាងគ្រប់គ្រាន់ ទាក់ទងនឹងបទល្មើសដែលចោទប្រកាន់ ត្រូវបញ្ជូនសំណុំរឿងនេះទៅកាន់អាជ្ញាធរដែលទទួលបន្ទុកការងារនេះ ដើម្បីជួយជំរុញដំណើរការនីតិវិធីដោយគ្មានការពន្យារពេល ឱ្យស្របតាមច្បាប់ និងនៅកន្លែងណាដែលសមស្រប អាចឃាត់ទុកនាវាពាក់ព័ន្ធនោះបាន
(ង) ត្រូវធានាថានៅកន្លែងណាដែលវិធានការនោះត្រូវបានបង្កើតឡើង សមស្របតាមច្បាប់នាវាដែលជាប់ពាក់ព័ន្ធក្នុងការចូលរួមចំណែកប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ហើយនាវានោះមិនអាចចូលរួមក្នុងការធ្វើនេសាទនៅសមុទ្រអន្តរជាតិបានរហូតដល់ពេលការដាក់ទណ្ឌកម្មសំខាន់ៗទាំងអស់ដោយរដ្ឋ ជាម្ចាស់ទង់ជាតិត្រូវបានបំពេញរួចរាល់។

២. រាល់ការស៊ើបអង្កេតនិងនីតិវិធីតុលាការត្រូវអនុវត្តឱ្យបានឆាប់។ ការដាក់ទណ្ឌកម្មដែលអាចអនុវត្តបានទាក់ទងទៅនឹងបទល្មើសត្រូវតែមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពក្នុងការគោរពច្បាប់និងមិនលើកទឹកចិត្តចំពោះបទល្មើសនានា ដើម្បីកុំឱ្យជនល្មើសទទួលបានផលប្រយោជន៍ពីសកម្មភាពនេសាទខុសច្បាប់របស់ពួកគេ។ វិធានការដែលអាចអនុវត្តបានចំពោះមេបញ្ជាការនិងមន្ត្រីផ្សេងទៀតរបស់នាវានេសាទ ត្រូវរាប់បញ្ចូលទាំងបទប្បញ្ញត្តិ ដែលអាចផ្តល់ការអនុញ្ញាតឱ្យបដិសេធ ដកហូត ឬព្យួរលិខិតអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការបម្រើការជាមេបញ្ជាការ ឬមន្ត្រីផ្សេងទៀតរបស់នាវានេសាទទាំងនោះ។

## មាត្រា២០. កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការអនុវត្តច្បាប់

១. រដ្ឋនានាត្រូវសហប្រតិបត្តិការដោយផ្ទាល់ ឬតាមរយៈអង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ ឬអនុតំបន់ ដើម្បីធានានូវការគោរពនិងការអនុវត្តតាមវិធានការគ្រប់គ្រង និងអភិរក្សថ្នាក់តំបន់ ឬអនុតំបន់នូវផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

២. រដ្ឋម្ចាស់ទង់ជាតិដែលធ្វើការស៊ើបអង្កេតមួយលើការចោទប្រកាន់ពីបទល្មើសលើវិធានការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ អាចស្នើសុំជំនួយពីរដ្ឋដទៃ ដែលការរួមសហការរបស់រដ្ឋនោះ មានសារៈសំខាន់ក្នុងដំណើរការការស៊ើបអង្កេត។ គ្រប់រដ្ឋទាំងអស់ត្រូវតែខិតខំប្រឹងប្រែងដើម្បីឆ្លើយតបនឹងសំណើសមហេតុផល ដែលបានធ្វើឡើងដោយរដ្ឋម្ចាស់ទង់ជាតិ ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតនោះ។

៣. រដ្ឋម្ចាស់ទង់ជាតិ អាចធ្វើការស៊ើបអង្កេតទាំងនោះដោយផ្ទាល់ ឬតាមរយៈការសហការជាមួយបណ្តារដ្ឋពាក់ព័ន្ធ ឬតាមរយៈអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់។ ព័ត៌មានស្តីពីវឌ្ឍនភាពនិង លទ្ធផលនៃការស៊ើបអង្កេតទាំងនោះ ត្រូវផ្តល់ឱ្យរដ្ឋទាំងអស់ដែលមានផលប្រយោជន៍ឬប៉ះពាល់ពីបទល្មើសនេសាទដែលចោទប្រកាន់ទាំងនោះ។

៤. រដ្ឋនានាត្រូវជួយគ្នាទៅវិញទៅមកក្នុងការកំណត់អត្តសញ្ញាណនាវា ដែលត្រូវបានរាយការណ៍ថាបានចូលរួមនិងកំពុងធ្វើសកម្មភាពដែលប៉ះពាល់ដល់ប្រសិទ្ធភាព នៃវិធានការគ្រប់គ្រងនិងអភិរក្សនៅថ្នាក់តំបន់ ឬអនុតំបន់ ឬសកលលោក។

៥. នៅក្នុងក្របខណ្ឌដែលអនុញ្ញាតដោយលិខិតបទដ្ឋាននិងច្បាប់ជាតិ រដ្ឋនានាត្រូវបង្កើតការរៀបចំឱ្យមានលទ្ធភាពក្នុងការផ្តល់ដល់អាជ្ញាធរកាត់ទោសនៃរដ្ឋដទៃទៀត នូវភស្តុតាងទាក់ទងនឹងការចោទប្រកាន់ពីករណីល្មើសលើវិធានការទាំងនោះ។

៦. នៅកន្លែងណាដែលមានមូលដ្ឋានសមស្របក្នុងការជឿជាក់ថា នាវាមួយនៅដែនសមុទ្រអន្តរជាតិបានចូលរួមក្នុងការនេសាទដោយគ្មានការអនុញ្ញាត នៅតំបន់ស្ថិតក្រោមដែនយុត្តាធិការរបស់រដ្ឋម្ចាស់ឆ្នេរ រដ្ឋម្ចាស់ទង់ជាតិរបស់នាវានោះត្រូវស៊ើបអង្កេតពេញលេញនិងជាបន្ទាន់ទៅលើរឿងនោះ នៅពេលមានការស្នើសុំពីរដ្ឋម្ចាស់ឆ្នេរនោះ។ រដ្ឋម្ចាស់ទង់ជាតិត្រូវសហការជាមួយរដ្ឋម្ចាស់ឆ្នេរក្នុងការចាត់វិធានការអនុវត្តសមស្របតាមករណីទាំងនោះនិងអាចអនុញ្ញាតឱ្យអាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋម្ចាស់ឆ្នេរឡើងទៅលើនាវា និងធ្វើអធិការកិច្ចនាវានៅដែនសមុទ្រអន្តរជាតិនោះតែម្តង។ កថាខណ្ឌនេះមិនមានព្យសនកម្មចំពោះមាត្រា១១១នៃអនុសញ្ញាទេ។

៧. រដ្ឋភាគីដែលជាសមាជិកនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ឬអនុតំបន់ ឬជាអ្នកចូលរួមនៅក្នុងក្រុមការងារគ្រប់គ្រងជលផលនៅថ្នាក់តំបន់ឬអនុតំបន់អាចអនុវត្តសកម្មភាពស្របទៅតាមច្បាប់អន្តរជាតិ ដោយរួមបញ្ចូលនូវការប្រើប្រាស់នីតិវិធីថ្នាក់តំបន់ឬអនុតំបន់ដែលបានបង្កើតឡើងសម្រាប់គោលបំណងនេះ ដើម្បីទប់ស្កាត់នាវាដែលបានចូលរួមសកម្មភាពដែលប៉ះពាល់ដល់ប្រសិទ្ធភាព ឬផ្ទុយទៅវិញ បានប្រព្រឹត្តល្មើសលើវិធានការគ្រប់គ្រង និងអភិរក្សទាំងនោះដែលបានបង្កើតឡើងដោយអង្គការ ឬក្រុមការងារស្តីពីការនេសាទនៅដែនសមុទ្រអន្តរជាតិនៅក្នុងតំបន់ ឬអនុតំបន់ រហូតទាល់តែមានចំណាត់ការសមស្រប ធ្វើឡើងដោយរដ្ឋម្ចាស់ទង់ជាតិ។

## មាត្រា២១. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអនុតំបន់ក្នុងការអនុវត្តច្បាប់

១. នៅក្នុងដែនសមុទ្រអន្តរជាតិណាមួយដែលស្ថិតនៅក្រោមអង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ ឬអនុតំបន់រដ្ឋភាគីដែលជាសមាជិកនៃអង្គការនោះ ឬរដ្ឋចូលរួមនៅក្នុងក្រុមការងារអាចឡើងទៅលើនិងធ្វើអធិការកិច្ចលើនាវានេសាទដែលបំពាក់ទង់ជាតិរបស់រដ្ឋភាគីដទៃទៀតនៃកិច្ចព្រមព្រៀងនេះ ស្របទៅតាមកថាខណ្ឌទី២ តាមរយៈមន្ត្រីអធិការកិច្ចរបស់ខ្លួនដែលបានអនុញ្ញាតត្រឹមត្រូវតាមច្បាប់កំណត់ ទោះណាជារដ្ឋភាគីនោះជាសមាជិកឬមិនមែនជាសមាជិករបស់អង្គការនោះ ឬក៏ជារដ្ឋចូលរួមឬមិនមែនជាសមាជិកនៃក្រុមការងារនោះ ក្នុងគោលបំណងធ្វើឱ្យប្រាកដថា ការគោរពតាមវិធានការគ្រប់គ្រង និងអភិរក្សជលស្តុកត្រីផ្លាស់ទីមធ្យមឬជលស្តុកត្រីផ្លាស់ទីឆ្ងាយ ដែលបានង្កើតឡើងដោយអង្គការឬក្រុមការងារនោះ។

២. តាមរយៈអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ រដ្ឋនានាត្រូវបង្កើតនីតិវិធីសម្រាប់ការឡើងឬធ្វើអធិការកិច្ចលើនាវាស្របទៅតាមកថាខណ្ឌទី១ ក៏ដូចជានីតិវិធីសម្រាប់អនុវត្តចំណុចផ្សេងទៀតនៃមាត្រានេះ។ នីតិវិធីទាំងនេះត្រូវស្របគ្នានឹងមាត្រានេះនិងនីតិវិធីជាមូលដ្ឋានដែលចែងក្នុងមាត្រា២២ និងមិនត្រូវរើសអើងចំពោះរដ្ឋ ដែលមិនមែនជាសមាជិករបស់អង្គការឬមិនមែនជារដ្ឋចូលរួមនៅក្នុងក្រុមការងារនោះ។ ការឡើងលើនាវានិងការធ្វើអធិការកិច្ចក៏ដូចជាសកម្មភាពពង្រឹងការអនុវត្តបន្តបន្ទាប់ណាមួយ ត្រូវតែធ្វើឡើងឱ្យស្របតាមនីតិវិធីទាំងនោះ។ រដ្ឋត្រូវផ្សព្វផ្សាយជាសាធារណៈនូវនីតិវិធីនានាដែលត្រូវបានបង្កើតឡើងស្របតាមកថាខណ្ឌនេះ។

៣. ប្រសិនបើរយៈពេល២ឆ្នាំនៃការអនុម័តកិច្ចព្រមព្រៀងនេះ អង្គការឬក្រុមការងារណាមួយមិនបានបង្កើតនីតិវិធីទាំងនោះទេ ការឡើងលើនាវានិងការធ្វើអធិការកិច្ចលើនាវាស្របតាមកថាខណ្ឌទី១ ក៏ដូចជាសកម្មភាពពង្រឹងការអនុវត្តបន្តបន្ទាប់ណាមួយ ត្រូវតែធ្វើឡើងដោយអនុលោមទៅតាមមាត្រានេះនិងនីតិវិធីជាមូលដ្ឋានដែលត្រូវបានចែងនៅក្នុងមាត្រា២២ នៅពេលដែលមិនទាន់មានការបង្កើតនីតិវិធីទាំងនោះនៅឡើយ។

៤. មុនពេលចាត់វិធានការតាមមាត្រានេះ រដ្ឋដែលធ្វើអធិការកិច្ចត្រូវជូនដំណឹងដោយផ្ទាល់ឬតាមរយៈអង្គការឬក្រុមការងារគ្រប់គ្រងជលផលពាក់ព័ន្ធនៅថ្នាក់តំបន់ឬអនុតំបន់ទៅឱ្យគ្រប់រដ្ឋទាំងអស់ដែលនាវា របស់រដ្ឋទាំងនោះធ្វើនេសាទនៅដែនសមុទ្រអន្តរជាតិ ស្ថិតក្នុងតំបន់ឬអនុតំបន់ ពីទម្រង់អត្តសញ្ញាណកម្ម ដែលបានចេញឱ្យមន្ត្រីអធិការកិច្ចដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ។ នាវាដែលត្រូវបានគេប្រើសម្រាប់ការធ្វើដំណើរនិងការធ្វើអធិការកិច្ចត្រូវមានសញ្ញាសម្គាល់ច្បាស់លាស់និងអាចកំណត់អត្តសញ្ញាណបានថាជាការបំពេញការងាររបស់រដ្ឋាភិបាល។ នៅពេលដែលក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះ រដ្ឋនានាត្រូវតែតែងតាំងអាជ្ញាធរសមស្របមួយ ដើម្បីទទួលការជូនដំណឹងជាផ្លូវការ ស្របតាមមាត្រានេះ និងត្រូវផ្សព្វផ្សាយជាសាធារណៈស្តីពីការតែងតាំងនេះតាមរយៈអង្គការឬក្រុមការងារគ្រប់គ្រងជលផលពាក់ព័ន្ធនៅថ្នាក់តំបន់ឬអនុតំបន់។

៥. យោងតាមការឡើងនិងការធ្វើអធិការកិច្ចលើនាវានៅកន្លែងណា ដែលមានមូលដ្ឋានច្បាស់លាស់ដើម្បីជឿជាក់ថានាវាមួយបានចូលរួមក្នុងសកម្មភាពណាមួយដែលផ្ទុយទៅនឹងវិធានការគ្រប់គ្រង និងអភិរក្សដូចមានចែងក្នុងកថាខណ្ឌទី១ រដ្ឋដែលធ្វើអធិការកិច្ចត្រូវថែរក្សាភស្តុតាងតាមដែលអាចធ្វើទៅបាន រួចត្រូវជូនដំណឹងជាផ្លូវការភ្លាមទៅរដ្ឋម្ចាស់ទង់ជាតិដែលត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តបទល្មើសនោះ។

៦. រដ្ឋម្ចាស់ទង់ជាតិត្រូវឆ្លើយតបទៅនឹងការជូនដំណឹងជាផ្លូវការ ដោយយោងតាមកថាខណ្ឌទី៥ នៅក្នុងរយៈពេល៣ថ្ងៃនៃថ្ងៃធ្វើការ ស្តីពីការទទួលបានសេចក្តីជូនដំណឹងនេះ ឬនៅក្នុងកំលុងពេលណាមួយផ្សេងទៀតដែលបានបញ្ជាក់នៅក្នុងនីតិវិធីដែលបានបង្កើតឡើង ស្របទៅតាមកថាខណ្ឌទី២ និងត្រូវចាត់វិធានការតាមចំណុចណាមួយដូចខាងក្រោម៖

   (ក) បំពេញកាតួកិច្ចរបស់ខ្លួនដូចមានចែងក្នុងមាត្រា១៩ ដោយមិនពន្យារពេលដើម្បីស៊ើបអង្កេត និងប្រសិនបើមានភស្តុតាងដូចការចោទ ត្រូវចាត់វិធានការចំពោះនាវានោះ។ ក្នុងករណីនេះ ត្រូវជូនដំណឹងភ្លាមៗ ទៅរដ្ឋដែលធ្វើអធិការកិច្ចនូវលទ្ធផលនៃការស៊ើបអង្កេតនិងការអនុវត្តច្បាប់

   (ខ) អនុញ្ញាតឱ្យរដ្ឋដែលធ្វើអធិការកិច្ចស៊ើបអង្កេត។

៧. នៅកន្លែងណាដែលរដ្ឋម្ចាស់ទង់ជាតិអនុញ្ញាតឱ្យរដ្ឋដែលធ្វើអធិការកិច្ចស៊ើបអង្កេត លើការចោទប្រកាន់ពីបទល្មើសមួយ រដ្ឋដែលធ្វើអធិការកិច្ចត្រូវធ្វើការចែករំលែកព័ត៌មានពីលទ្ធផលនៃការស៊ើបអង្កេតនោះដល់រដ្ឋម្ចាស់ទង់ជាតិដោយគ្មានការពន្យារពេល។ រដ្ឋម្ចាស់ទង់ជាតិត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីចាត់វិធានការអនុវត្តច្បាប់ចំពោះនាវានោះ ប្រសិនបើមានភស្តុតាងដូចការចោទប្រកាន់។ វិធីម្យ៉ាងទៀត រដ្ឋម្ចាស់ទង់ជាតិអាចអនុញ្ញាតឱ្យរដ្ឋដែលធ្វើអធិការកិច្ចចាត់វិធានការអនុវត្តច្បាប់ ដូចបានបញ្ជាក់ប្រាប់ដល់នាវាពីវិធានការទាំងនោះ ស្របតាមសិទ្ធិនិងកាតព្វ កិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ ដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ។

៨. ចំពោះការធ្វើអធិការកិច្ចនៅលើនាវា នៅពេលដែលមានព័ត៌មានច្បាស់លាស់អាចជឿជាក់បានថា នាវានេសាទមួយបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ហើយរដ្ឋម្ចាស់ទង់ជាតិមិនបានឆ្លើយតបឬចាត់វិធានការដូចដែលបានតម្រូវនៅក្រោមកថាខណ្ឌទី៦និងទី៧ មន្ត្រីអធិការកិច្ចអាចស្ថិតនៅលើនាវា និងថែរក្សាភស្តុតាង និងអាចតម្រូវឱ្យមេបញ្ជាការនាវានោះជួយស៊ើបអង្កេតបន្ថែមទៀត។ ក្នុងករណីចាំបាច់ អាចនាំយកនាវានោះដោយគ្មានការពន្យារពេលទៅកាន់កំពង់ផែដែលនៅជិតបំផុតឬទៅកាន់កំពង់ផែណាមួយផ្សេងទៀត ដូចដែលបានបញ្ជាក់នៅក្នុង

នីតិវិធីដែលបានបង្កើតឡើងស្របទៅតាមកថាខណ្ឌទី២។ រដ្ឋដែលធ្វើអធិការកិច្ច ត្រូវជូនដំណឹងភ្លាមៗទៅរដ្ឋម្ចាស់ទង់ជាតិពីឈ្មោះរបស់កំពង់ផែដែលនាវានោះត្រូវបានរក្សាទុក។ រដ្ឋដែលធ្វើអធិការកិច្ចនិងរដ្ឋម្ចាស់ទង់ជាតិ ព្រមទាំងរដ្ឋម្ចាស់កំពង់ផែចាំបាច់ត្រូវធានា តាមការសមស្របដល់សុខុមាលភាពរបស់បុគ្គលិកនាវាដោយមិនប្រកាន់សញ្ជាតិ។

៩. រដ្ឋដែលធ្វើអធិការកិច្ចត្រូវជូនដំណឹងទៅរដ្ឋម្ចាស់ទង់ជាតិនិងអង្គការពាក់ព័ន្ធ ឬរដ្ឋចូលរួមនៅក្នុងក្រុមការងារនោះពីលទ្ធផលនៃការស៊ើបអង្កេតណាមួយបន្ថែមទៀត។

១០. រដ្ឋដែលធ្វើអធិការកិច្ចត្រូវតម្រូវឱ្យមន្ត្រីអធិការកិច្ចរបស់ខ្លួនសង្កេតជាទូទៅ តាមបទប្បញ្ញត្តិ នីតិវិធី និងការអនុវត្តជាលក្ខណៈអន្តរជាតិ ទៅលើសុវត្ថិភាពរបស់នាវានិងក្រុមបុគ្គលិកនាវា ដោយកាត់បន្ថយក្នុងកម្រិតអប្បបរមានៃការរំខានក្នុងការធ្វើនេសាទនិងនៅក្នុងវិសាលភាពដែលអាចអនុវត្តបាន ត្រូវចៀសវាងសកម្មភាពដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់គុណភាពផលនេសាទនៅលើនាវា។ រដ្ឋដែលធ្វើអធិការកិច្ចត្រូវតែធានាថាការឡើងលើនាវានិងការធ្វើអធិការកិច្ចមិនធ្វើឡើងនៅក្នុងលក្ខណៈមួយដែលជាការរំលោភបំពានដល់នាវាណាមួយនោះទេ។

១១. ក្នុងគោលបំណងនៃមាត្រានេះ ការរំលោភបំពានធ្ងន់ធ្ងរមានន័យចំពោះ៖

(ក) ការនេសាទដោយប្រើប្រាស់ឯកសារផុតសុពលភាពដូចជា អាជ្ញាបណ្ណនេសាទ ការអនុញ្ញាតជាផ្លូវការ ឬលិខិតអនុញ្ញាតដែលបានចេញដោយរដ្ឋម្ចាស់ទង់ជាតិស្របទៅតាមមាត្រា១៨ កថាខណ្ឌទី៣(ក)

(ខ) ការមិនបានរក្សាទុកនូវកំណត់ត្រាត្រឹមត្រូវស្តីពីទិន្នន័យផលនេសាទនិងទិន្នន័យពាក់ព័ន្ធផលនេសាទដែលបានតម្រូវដោយអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ពាក់ព័ន្ធ ឬរាយការណ៍ខុសធ្ងន់ធ្ងរពីផលនេសាទ ផ្ទុយពីតម្រូវការរាយការណ៍អំពីផលនេសាទរបស់អង្គការឬក្រុមការងារនោះ

(គ) ការនេសាទនៅក្នុងតំបន់ហាមឃាត់ ការនេសាទនៅក្នុងរដូវបិទនេសាទ ឬការធ្វើនេសាទដោយគ្មានឬក្រោយពីអស់កូតា ដែលត្រូវបានបង្កើតឡើងដោយអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ពាក់ព័ន្ធ

(ឃ) ការនេសាទទៅលើផលស្តុកមួយដែលត្រូវបានដាក់បម្រាមឬត្រូវបានហាមឃាត់ក្នុងការធ្វើនេសាទ

(ង) ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់

(ច) ការបន្លំឬលាក់បាំងការដាក់សញ្ញាសម្គាល់ អត្តសញ្ញាណ ឬការចុះបញ្ជីនាវា

(ឆ) ការលាក់បាំង ការជ្រៀតជ្រែក ឬការបំបាត់ភស្តុតាងទាក់ទងដល់ការស៊ើបអង្កេត

(ជ) ការរំលោភបំពានញឹកញាប់ដែលបានបំពានយ៉ាងធ្ងន់ធ្ងរទៅលើវិធានការគ្រប់គ្រងនិងអភិរក្ស

(ឈ) ការរំលោភបំពានដទៃទៀត ដូចបានបញ្ជាក់នៅក្នុងនីតិវិធីដែលបានបង្កើតឡើងដោយអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ពាក់ព័ន្ធ។

១២. ថ្វីបើមានបទប្បញ្ញត្តិដទៃចែងក្នុងមាត្រានេះក៏ដោយ ក៏រដ្ឋម្ចាស់ទង់ជាតិអាចធ្វើសកម្មភាពបំពេញកាតព្វកិច្ចរបស់ខ្លួនបានគ្រប់ពេល ដូចមានចែងក្នុងមាត្រា១៩ ទាក់ទងទៅនឹងការចោទប្រកាន់ពីការរំលោភបំពាន។ នៅពេលដែលនាវាស្ថិតនៅក្រោមការកំណត់របស់រដ្ឋដែលធ្វើអធិការកិច្ចតាមការស្នើសុំពីរដ្ឋម្ចាស់ទង់ជាតិ រដ្ឋដែលធ្វើអធិការកិច្ចត្រូវដោះលែងនាវានោះទៅឱ្យរដ្ឋជាម្ចាស់ទង់ជាតិវិញ ដោយភ្ជាប់ជាមួយនូវព័ត៌មានពេញលេញស្តីពីវឌ្ឍនភាពនិងលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន។

១៣. មាត្រានេះគ្មានព្យសនកម្មចំពោះសិទ្ធិរបស់រដ្ឋម្ចាស់ទង់ជាតិ ដើម្បីចាត់វិធានការណាមួយរាប់បញ្ចូលទាំងនីតិវិធីដាក់ទោសទណ្ឌ ស្របទៅតាមច្បាប់របស់រដ្ឋខ្លួននោះទេ។

១៤. មាត្រានេះអនុវត្តដោយមានការកែសម្រួលដោយមិនឱ្យប៉ះពាល់ដល់ន័យដើម ប្រសិនបើមានការចាំបាច់ ចំពោះការឡើងនិងការធ្វើអធិការកិច្ចលើនាវា ដោយរដ្ឋដែលជាសមាជិករបស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬ

អនុតំបន់ ឬរដ្ឋចូលរួមក្នុងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ និងដែលមានព័ត៌មានច្បាស់លាស់អាចជឿជាក់បានថានាវានេសាទដែលបំពាក់ទង់ជាតិរបស់រដ្ឋដែលជាភាគីមួយទៀតបានចូលរួមក្នុងសកម្មភាពណាមួយដែលផ្ទុយទៅនឹងវិធានការគ្រប់គ្រង និងអភិរក្សពាក់ព័ន្ធដូច មានចែងក្នុងកថាខណ្ឌទី១ នៅក្នុងដែនសមុទ្រអន្តរជាតិដែលគ្រប់គ្រងដោយអង្គការឬក្រុមការងារនោះ ដែលកើតមានឡើងនៅក្រោយពេលនាវាទាំងនោះបានចូលទៅក្នុងតំបន់មួយ ដែលស្ថិតនៅក្រោមដែនយុត្តាធិការជាតិរបស់រដ្ឋដែលធ្វើអធិការកិច្ចក្នុងពេលធ្វើដំណើរទៅនេសាទនោះ។

១៥. នៅកន្លែងដែលអង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ ឬអនុតំបន់បានបង្កើតយន្តការជំនួសមួយដែលបានផ្តល់កាតព្វកិច្ចប្រកបដោយប្រសិទ្ធភាពនៅក្រោមកិច្ចព្រមព្រៀងនេះ ដល់សមាជិករបស់អង្គការឬរដ្ឋចូលរួមក្នុងក្រុមការងារនោះ ដើម្បីធានាដល់ការអនុវត្តវិធានការគ្រប់គ្រងនិងអភិរក្ស សមាជិករបស់អង្គការឬរដ្ឋចូលរួមនៅក្នុងក្រុមការងារនោះ អាចយល់ព្រមដើម្បីកំណត់ព្រំដែននៃការអនុវត្តរបស់ពួកគេ ដូចមានចែងក្នុងកថាខណ្ឌទី១ ទាក់ទងនឹងវិធានការគ្រប់គ្រង និងអភិរក្សដែលត្រូវបានបង្កើតឡើងនៅក្នុងតំបន់ដែន សមុទ្រអន្តរជាតិដែលពាក់ព័ន្ធ។

១៦. វិធានការដែលត្រូវបានលើកឡើង ដោយរដ្ឋមិនមែនជារដ្ឋម្ចាស់ទង់ជាតិ ទាក់ទងទៅនឹងនាវាដែលធ្វើសកម្មភាពផ្ទុយនឹងវិធានការគ្រប់គ្រងនិងអភិរក្សថ្នាក់តំបន់ឬអនុតំបន់ ត្រូវកំណត់ឱ្យសមមាត្រនឹងស្ថានទម្ងន់ទោសនៃការរំលោភបំពាននោះ។

១៧. នៅកន្លែងដែលមានព័ត៌មានសមហេតុផលក្នុងការសង្ស័យថានាវានេសាទ នៅក្នុងដែនសមុទ្រអន្តរជាតិមិនមានសញ្ជាតិ រដ្ឋនោះអាចឡើងនិងធ្វើអធិការកិច្ចលើនាវានោះបាន។ នៅកន្លែងណាដែលមានភស្តុតាងសមល្មមនិងជឿជាក់បាន រដ្ឋនោះអាចចាត់វិធានការសមស្របតាមច្បាប់អន្តរជាតិ។

១៨. រដ្ឋនានាត្រូវទទួលខុសត្រូវចំពោះការខូចខាត ឬបាត់បង់ដែលកើតឡើងចំពោះនាវានេសាទនោះចំពោះការចាត់វិធានការស្របតាមមាត្រានេះ នៅពេលដែលការធ្វើអធិការកិច្ចនោះមិនស្របច្បាប់ឬលើសពីការតម្រូវឱ្យធ្វើដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះ នៅពេលព័ត៌មានដែលមាននោះមិនគ្រប់គ្រាន់។

## មាត្រា២២. នីតិវិធីជាមូលដ្ឋានសម្រាប់ការឡើងនិងការធ្វើអធិការកិច្ចលើនាវាស្របតាម

១. រដ្ឋដែលធ្វើអធិការកិច្ចត្រូវធានាថាមន្ត្រីអធិការកិច្ចរបស់ខ្លួនជាមន្ត្រីដែលមាននីតិសម្បទាត្រឹមត្រូវដូចខាងក្រោម៖

(ក) បង្ហាញលិខិតសម្គាល់ខ្លួនទៅមេបញ្ជាការនាវានិងឯកសារស្តីពីវិធានការគ្រប់គ្រងនិងអភិរក្សពាក់ព័ន្ធ ឬច្បាប់ និងបទប្បញ្ញត្តិដែលអនុវត្តនៅក្នុងដែនសមុទ្រអន្តរជាតិជាធរមាន ឱ្យស្របតាមវិធានការទាំងនោះ

(ខ) ផ្តល់ដំណឹងទៅរដ្ឋម្ចាស់ទង់ជាតិនៅពេលឡើង និងធ្វើអធិការកិច្ចលើនាវា

(គ) មិនរំខានដល់មេបញ្ជាការនាវាក្នុងការទាក់ទងជាមួយអាជ្ញាធរនៃរដ្ឋម្ចាស់ទង់ជាតិ ក្នុងពេលឡើងនិងធ្វើអធិការកិច្ចលើនាវា

(ឃ) ផ្តល់របាយការណ៍មួយច្បាប់ស្តីពីការឡើង និងការធ្វើអធិការកិច្ចលើនាវា ទៅមេបញ្ជាការនាវានិងទៅអាជ្ញាធររដ្ឋម្ចាស់ទង់ជាតិ ដោយកត់ត្រានៅក្នុងរបាយការណ៍នោះនូវការជំទាស់ ឬការអះអាងណាមួយដែលមេបញ្ជាការនាវាចង់ឱ្យដាក់នៅក្នុងរបាយការណ៍នោះ

(ង) ចាកចេញពីនាវាភ្លាមក្រោយពីបានធ្វើអធិការកិច្ចចប់សព្វគ្រប់ ប្រសិនជាមន្ត្រីអធិការកិច្ចរកមិនឃើញមានភស្តុតាងស្តីពីការរំលោភបំពានធ្ងន់ធ្ងរណាមួយនោះទេ

(ច) ជៀសវាងការប្រើប្រាស់កម្លាំងប្រដាប់អាវុធ លើកលែងតែក្នុងករណីចាំបាច់ដើម្បីធានាសុវត្ថិភាពដល់មន្ត្រីអធិការកិច្ចនិងកន្លែងដែលមន្ត្រីអធិការកិច្ចត្រូវបានរារាំងក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ កម្រិតនៃកម្លាំងប្រដាប់អាវុធដែលត្រូវប្រើមិនត្រូវលើសពីតម្រូវការជាក់ស្ដែងឡើយ។

២. មន្ត្រីអធិការកិច្ចដែលទទួលបានការអនុញ្ញាតត្រឹមត្រូវពីរដ្ឋដែលធ្វើអធិការកិច្ច ត្រូវមានសិទ្ធិអំណាចដើម្បីធ្វើអធិការកិច្ចនាវា អាជ្ញាបណ្ណនេសាទ ឧបករណ៍នេសាទ សម្ភារៈនេសាទ កំណត់ត្រា បរិក្ខារ ត្រី និងផលិតផលត្រី និងឯកសារពាក់ព័ន្ធណាមួយដែលចាំបាច់ សម្រាប់ផ្ទៀងផ្ទាត់ការអនុវត្តតាមវិធានការគ្រប់គ្រង និងអភិរក្សពាក់ព័ន្ធ។

៣. រដ្ឋម្ចាស់ទង់ជាតិត្រូវធានាថាមេបញ្ជាការរបស់នាវា៖

(ក) ទទួលយកនិងសម្របសម្រួលដល់ការឡើងលើនាវាភ្លាមៗនិងប្រកបដោយសុវត្ថិភាពចំពោះមន្ត្រីអធិការកិច្ច

(ខ) សហការនិងជួយការធ្វើអធិការកិច្ចលើនាវាឱ្យស្របតាមនីតិវិធីទាំងនោះ

(គ) មិនរារាំង មិនបំភិតបំភ័យ ឬមិនជ្រៀតជ្រែកមន្ត្រីអធិការកិច្ចក្នុងការបំពេញភារកិច្ចពួកគេ

(ឃ) អនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចទាក់ទងជាមួយអាជ្ញាធរនៃរដ្ឋម្ចាស់ទង់ជាតិ និងរដ្ឋធ្វើអធិការកិច្ចក្នុងកំឡុងពេលនៃការឡើងនិងការធ្វើអធិការកិច្ចលើនាវានោះ

(ង) ផ្តល់បរិក្ខារសមស្របរួមទាំងចំណីអាហារ និងការទទួលឱ្យស្នាក់នៅដល់មន្ត្រីអធិការកិច្ចនៅកន្លែងណាដែលសមស្រប

(ច) សម្របសម្រួលការចាកចេញពីនាវាប្រកបដោយសុវត្ថិភាពដល់មន្ត្រីអធិការកិច្ច។

៤. នៅពេលដែលមេបញ្ជាការនាវាបដិសេធមិនឱ្យឡើង និងធ្វើអធិការកិច្ចលើនាវាស្របទៅនឹងមាត្រានេះនិងមាត្រា ២១ លើកលែងតែក្នុងកាលៈទេសៈចាំបាច់ រដ្ឋម្ចាស់ទង់ជាតិត្រូវសុំពន្យារពេលការឡើង និងធ្វើអធិការកិច្ច ដូចបានកំណត់ក្នុងច្បាប់ នីតិវិធី និងការអនុវត្តជាអន្តរជាតិទាក់ទងទៅនឹងសុវត្ថិភាពលើផ្ទៃសមុទ្រ និងត្រូវណែនាំមេបញ្ជាការនាវានោះឱ្យយល់ព្រមទទួលយកការឡើងលើ និងការធ្វើអធិការកិច្ចនៅលើនាវា។ ប្រសិនបើមេបញ្ជាការនាវានោះនៅតែមិនធ្វើតាមការណែនាំ រដ្ឋម្ចាស់ទង់ជាតិត្រូវព្យួរការអនុញ្ញាតការធ្វើនេសាទនិងបញ្ជានាវានោះឱ្យត្រឡប់ទៅកំពង់ផែរដ្ឋរបស់ខ្លួនវិញភ្លាម។ រដ្ឋម្ចាស់ទង់ជាតិត្រូវផ្តល់ព័ត៌មានទៅរដ្ឋដែលធ្វើអធិការកិច្ចចំពោះសកម្មភាពដែលខ្លួនបានធ្វើ នៅពេលដែលកើតឡើងនូវហេតុការណ៍ដូចមានចែងក្នុងកថាខណ្ឌនេះ។

## មាត្រា២៣. វិធានការដែលត្រូវប្រកាន់យកដោយរដ្ឋម្ចាស់កំពង់ផែ

១. រដ្ឋម្ចាស់កំពង់ផែមានសិទ្ធិ និងកាតព្វកិច្ចចាត់វិធានការស្របទៅតាមច្បាប់អន្តរជាតិ ដើម្បីជំរុញប្រសិទ្ធភាពវិធានការគ្រប់គ្រងនិងអភិរក្សថ្នាក់តំបន់ឬអនុតំបន់និងសកលលោក។ នៅពេលចាត់វិធានការទាំងនោះ រដ្ឋម្ចាស់កំពង់ផែមិនត្រូវរើសអើងប្រឆាំងចំពោះនាវារបស់រដ្ឋណាមួយឡើយ។

២. រដ្ឋម្ចាស់កំពង់ផែអាចត្រួតពិនិត្យឯកសារ ឧបករណ៍នេសាទ និងផលនេសាទនៅលើនាវានេសាទ នៅពេលនាវាទាំងនោះស្ថិតនៅកំពង់ផែរបស់ខ្លួនដោយស្ម័គ្រចិត្តឬនៅក្នុងចំណតនៅសមុទ្រក្រៅ។

៣. រដ្ឋនានាអាចអនុម័តច្បាប់ដែលផ្តល់អំណាចដល់អាជ្ញាធរជាតិពាក់ព័ន្ធ ដើម្បីហាមឃាត់ការឡើងផលនេសាទនៅកំពង់ផែនិងការផ្ទេរផលនេសាទនៅកន្លែងណាដែលផលនេសាទនោះត្រូវបាននេសាទ ក្នុងលក្ខណៈដែលធ្វើឱ្យអន្តរាយដល់ប្រសិទ្ធភាពរបស់វិធានការគ្រប់គ្រងនិងអភិរក្សថ្នាក់តំបន់ឬអនុតំបន់ ឬសកលលោកនៅក្នុងដែនសមុទ្រអន្តរជាតិ។

៤. មាត្រានេះនឹងមិនប៉ះពាល់ដល់ការអនុវត្តដោយរដ្ឋដែលមានដែនអធិបតេយ្យភាពចំពោះកំពង់ផែ ដែលស្ថិតក្នុងដែនដីរបស់ខ្លួន ដោយអនុលោមទៅតាមច្បាប់អន្តរជាតិ។

## ផ្នែកទី៧. តម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍ

## មាត្រា២៤. ការទទួលស្គាល់តម្រូវការពិសេសរបស់រដ្ឋកំពុងអភិវឌ្ឍ

១. រដ្ឋនានាត្រូវផ្តល់ការទទួលស្គាល់ពេញលេញចំពោះតម្រូវការពិសេសរបស់រដ្ឋកំពុងអភិវឌ្ឍ ទាក់ទងនឹងការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ និងការអភិវឌ្ឍជលផលសម្រាប់ផលស្តុកទាំងនោះ។ ដើម្បីសម្រេចបានទិសដៅនេះ រដ្ឋនានាត្រូវផ្តល់ជំនួយដល់រដ្ឋកំពុងអភិវឌ្ឍដោយផ្ទាល់ឬតាមរយៈកម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ ទីភ្នាក់ងារឯកទេសអង្គការសម្របសម្រួលបរិស្ថានពិភពលោក គណៈកម្មាធិការអភិវឌ្ឍដោយនិរន្តរភាព និងអង្គការនិងស្ថាប័នថ្នាក់តំបន់និងអន្តរជាតិពាក់ព័ន្ធដទៃទៀត។

២. ដើម្បីធ្វើឱ្យកិច្ចសហប្រតិបត្តិការក្នុងការបង្កើតវិធានការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ រដ្ឋនានាត្រូវគិតទៅដល់តម្រូវការពិសេសចំពោះរដ្ឋកំពុងអភិវឌ្ឍដែលមានជាពិសេសដូចជា៖

(ក) ភាពងាយរងគ្រោះរបស់រដ្ឋកំពុងអភិវឌ្ឍដែលពឹងអាស្រ័យលើការធ្វើអាជីវកម្មធនធានមានជីវិត នៅក្នុងសមុទ្រ រួមបញ្ចូលទាំងការផ្តល់អាហារូបត្ថម្ភមួយផ្នែក ឬតាមតម្រូវការរបស់ប្រជាជននៃរដ្ឋកំពុងអភិវឌ្ឍទាំងនោះ

(ខ) តម្រូវការដើម្បីជៀសឱ្យផុតពីផលប៉ះពាល់អវិជ្ជមាន និងធានាដល់ការធ្វើនេសាទរបស់អ្នកនេសាទសម្រាប់តែចិញ្ចឹមជីវិត ខ្នាតតូច ឬអ្នកនេសាទជាលក្ខណៈប្រពៃណី និងស្ត្រីដែលជាកម្មករនេសាទ រួមទាំងជនជាតិដើមភាគតិចនៅក្នុងរដ្ឋកំពុងអភិវឌ្ឍ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍដែលជាកោះតូចៗ

(គ) តម្រូវការដើម្បីធានាថាវិធានការទាំងអស់នោះនឹងមិនដាក់បន្ទុកធ្ងន់ធ្ងរ បង្កឡើងដោយលទ្ធផលនៃការអនុវត្តសកម្មភាពអភិរក្សនេះត្រូវបានផ្ទេរដោយផ្ទាល់ឬដោយប្រយោលទៅកាន់រដ្ឋកំពុងអភិវឌ្ឍនោះទេ

## មាត្រា២៥. ទម្រង់នៃកិច្ចសហការជាមួយរដ្ឋកំពុងអភិវឌ្ឍ

១. រដ្ឋនានាត្រូវសហការគ្នាដោយផ្ទាល់ឬតាមរយៈអង្គការថ្នាក់តំបន់ឬអនុតំបន់ ឬសកលលោក៖

(ក) ដើម្បីពង្រឹងសមត្ថភាពរបស់រដ្ឋកំពុងអភិវឌ្ឍ ជាពិសេស រដ្ឋមានការអភិវឌ្ឍតិចតួចជាងគេក្នុងចំណោមរដ្ឋកំពុងអភិវឌ្ឍទាំងនោះ ឱ្យធ្វើការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយនិងអភិវឌ្ឍការធ្វើនេសាទរបស់ពួកគេលើផលស្តុកទាំងនោះ

(ខ) ដើម្បីជួយដល់រដ្ឋកំពុងអភិវឌ្ឍ ជាពិសេស រដ្ឋមានការអភិវឌ្ឍតិចតួចជាងគេ ក្នុងចំណោមរដ្ឋកំពុងអភិវឌ្ឍនិងរដ្ឋកំពុងអភិវឌ្ឍដែលជាកោះតូចៗ ដើម្បីឱ្យរដ្ឋទាំងនោះចូលរួមនៅក្នុងការធ្វើនេសាទផលស្តុកក្នុងដែនសមុទ្រអន្តរជាតិ ដោយរួមទាំងការសម្របសម្រួលឱ្យរដ្ឋទាំងនោះអាចធ្វើនេសាទដូចមានចែងក្នុងមាត្រា៥និងមាត្រា១១

(គ) សម្របសម្រួលការចូលរួមរបស់រដ្ឋកំពុងអភិវឌ្ឍជាមួយអង្គការនិងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់។

២. កិច្ចសហការជាមួយរដ្ឋកំពុងអភិវឌ្ឍក្នុងគោលបំណងដូចមានចែងក្នុងមាត្រានេះ ត្រូវដាក់បញ្ចូលបទប្បញ្ញត្តិនៃជំនួយហិរញ្ញវត្ថុ ជំនួយការនានាទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស ជំនួយការបច្ចេកទេស ការផ្ទេរបច្ចេកវិទ្យា រួមទាំងការចូលរួមធ្វើពាណិជ្ជកម្មរួមគ្នា និងផ្តល់សេវាប្រឹក្សានិងពិគ្រោះយោបល់។

៣. ជំនួយទាំងនេះត្រូវបានកំណត់ក្នុងគោលដៅច្បាស់លាស់ មានជាអាទិ៍៖

(ក) ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម ឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ តាមរយៈការប្រមូល រាយការណ៍ ផ្ទៀងផ្ទាត់ ការផ្លាស់ប្តូរ និងការវិភាគទិន្នន័យជលផល និងព័ត៌មានពាក់ព័ន្ធ

(ខ) ការវាយតម្លៃផលស្តុកនិងការស្រាវជ្រាវវិទ្យាសាស្ត្រ

(គ) ការតាមដាន ការត្រួតពិនិត្យ ការអង្កេត ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ដោយរួមមានដូចជាវគ្គបណ្តុះបណ្តាលនិងការកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋាន ការអភិវឌ្ឍ និងមូលនិធិនៃកម្មវិធីអ្នកសង្កេតការថ្នាក់ជាតិ ថ្នាក់តំបន់ និងការចូលរួមប្រើបច្ចេកវិទ្យានិងសម្ភារៈ។

## មាត្រា២៦. ជំនួយពិសេសក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ

១. រដ្ឋទាំងអស់ត្រូវសហការបង្កើតមូលនិធិពិសេស ដើម្បីជួយដល់បណ្តារដ្ឋកំពុងអភិវឌ្ឍក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ដោយរួមបញ្ចូលទាំងការជួយដល់បណ្តារដ្ឋទាំងនោះក្នុងការបង់ថ្លៃចំណាយដែលកើតឡើងក្នុងការចូលរួមក្នុងដំណើរការនៃការដោះស្រាយវិវាទ ក្នុងករណីដែលរដ្ឋនេះគឺជារដ្ឋភាគី។

២. រដ្ឋនិងអង្គការអន្តរជាតិទាំងអស់ គួរតែជួយដល់បណ្តារដ្ឋកំពុងអភិវឌ្ឍក្នុងការបង្កើតអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ថ្មី ឬក្នុងការពង្រឹងអង្គការឬក្រុមការងារដែលមានស្រាប់សម្រាប់ការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

# ផ្នែកទី៨. ការដោះស្រាយវិវាទដោយសន្តិវិធី

## មាត្រា២៧. កាតព្វកិច្ចដើម្បីដោះស្រាយវិវាទដោយសន្តិវិធី

រដ្ឋទាំងអស់មានកាតព្វកិច្ចដោះស្រាយវិវាទរបស់ខ្លួន តាមរយៈការចរចា ការស៊ើបអង្កេត ការសម្រុះសម្រួល ការផ្សះផ្សា អាជ្ញាកណ្តាល ការដោះស្រាយតាមតុលាការឬតាមរយៈភ្នាក់ងារឬការរៀបចំថ្នាក់តំបន់ ឬមធ្យោបាយសន្តិវិធីផ្សេងទៀតតាមជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ។

## មាត្រា២៨. ការបង្ការវិវាទ

រដ្ឋនានាត្រូវសហការគ្នាដើម្បីទប់ស្កាត់វិវាទ។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋទាំងអស់ត្រូវឯកភាពគ្នាលើនីតិវិធីនៃការសម្រេចចិត្តយ៉ាងរហ័ស និងប្រកបដោយប្រសិទ្ធភាពនៅក្នុងបណ្តាអង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ និងត្រូវពង្រឹងនីតិវិធីនៃការសម្រេចចិត្តដែលមានស្រាប់ក្នុងករណីចាំបាច់។

## មាត្រា២៩. វិវាទផ្នែកបច្ចេកទេស

នៅពេលដែលវិវាទពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស រដ្ឋសាមីទាំងអស់អាចបញ្ជូនករណីទំនាស់នេះ ទៅឱ្យក្រុមការងារចំពោះកិច្ចរបស់ខ្លួនដែលបានបង្កើតជាអ្នកដោះស្រាយ។ ក្រុមការងារចំពោះកិច្ចត្រូវឆ្លងយោបល់រដ្ឋសាមី និងត្រូវព្យាយាមដោះស្រាយបញ្ហាជាប្រញាប់ ដោយគ្មានជំនួយពីនីតិវិធីច្បាប់ សម្រាប់ការដោះស្រាយវិវាទទាំងនោះ។

## មាត្រា៣០. នីតិវិធីដោះស្រាយវិវាទ

១. បទប្បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងការដោះស្រាយវិវាទ ដែលបានកំណត់នៅក្នុងផ្នែកទី១៥នៃអនុសញ្ញា ត្រូវអនុវត្តដោយមានការកែសម្រួលដោយមិនឱ្យប៉ះពាល់ដល់ន័យដើម ប្រសិនបើមានការចាំបាច់ចំពោះវិវាទរវាងរដ្ឋភាគីទាំងឡាយនៅក្នុងកិច្ចព្រមព្រៀងនេះដែលទាក់ទងនឹងការបកស្រាយនិងការអនុវត្តនូវកិច្ចព្រមព្រៀងនេះ ថាតើពួកគេជាភាគីក្នុងអនុសញ្ញាដែរឬទេ។

២. បទប្បញ្ញត្តិទាំងឡាយដែលទាក់ទងទៅនឹងការដោះស្រាយវិវាទ ដែលបានកំណត់នៅក្នុងផ្នែកទី១៥នៃអនុសញ្ញា ត្រូវអនុវត្តជម្រើសដូចគ្នាចំពោះវិវាទណាមួយរវាងរដ្ឋភាគីទាំងឡាយនៅក្នុងកិច្ចព្រមព្រៀងនេះជាមួយនឹងការបកស្រាយនិងការអនុវត្តនូវកិច្ចព្រមព្រៀងជលផលថ្នាក់តំបន់ឬអនុតំបន់និងសកលលោក ពាក់ព័ន្ធនឹងផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយដែលខ្លួនជាភាគី រួមទាំងវិវាទណាមួយពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិរក្សផលស្តុកទាំងនោះ ទោះបីជាពួកគេជាភាគីឬមិនមែនជាភាគីនៃអនុសញ្ញាក៏ដោយ។

៣. នីតិវិធីណាមួយដែលទទួលយកដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងនិងអនុសញ្ញា អនុលោមតាមមាត្រា២៨៧នៃអនុសញ្ញា ត្រូវអនុវត្តចំពោះការដោះស្រាយវិវាទទាំងឡាយដែលចែងនៅក្នុងផ្នែកនេះ លើកលែងតែរដ្ឋភាគីបានចុះហត្ថលេខាផ្តល់សច្ចាប័ន ឬយល់ព្រមលើកិច្ចព្រមព្រៀងនេះ ឬទទួលយកនីតិវិធីមួយផ្សេងទៀត អនុលោមតាមមាត្រា២៨៧ សម្រាប់ការដោះស្រាយវិវាទទាំងឡាយនៅក្នុងផ្នែកនេះនៅគ្រប់កាលៈទេសៈ។

៤. រដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះដែលមិនមែនជាភាគីនៃអនុសញ្ញា នៅពេលបានចុះហត្ថលេខាផ្តល់សច្ចាប័ន ឬយល់ព្រមលើកិច្ចព្រមព្រៀងនេះ ឬក្រោយមកត្រូវមានសេរីភាពក្នុងការជ្រើសរើសតាមមធ្យោបាយមួយឬច្រើនជាលាយលក្ខណ៍អក្សរដូចបានចែងក្នុងមាត្រា២៨៧កថាខណ្ឌទី១ នៃអនុសញ្ញាសម្រាប់ការដោះស្រាយវិវាទដែលកើតឡើងក្នុងផ្នែកនេះបានគ្រប់ពេល។ មាត្រា២៨៧ ត្រូវអនុវត្តចំពោះសេចក្តីប្រកាសនេះ ក៏ដូចជាចំពោះវិវាទណាមួយដែលប្រកាសមិនបានគ្របដណ្តប់ចំពោះរដ្ឋជាភាគី។ ដើម្បីគោលបំណងនៃការផ្សះផ្សានិងអាជ្ញាកណ្តាលដែលអនុលោមតាមឧបសម្ព័ន្ធទី៥ ទី៧ និងទី៨នៃអនុសញ្ញា រដ្ឋនោះត្រូវមានសិទ្ធិស្នើសុំដាក់បញ្ចូលឈ្មោះអ្នកផ្សះផ្សា អាជ្ញាកណ្តាល និងជំនាញការទៅក្នុងបញ្ជីដូចមានយោងនៅក្នុងឧបសម្ព័ន្ធទី៥ មាត្រា២ និងឧបសម្ព័ន្ធទី៧ មាត្រា២ និងឧបសម្ព័ន្ធទី៨ មាត្រា២ សម្រាប់ការដោះស្រាយវិវាទដែលកើតឡើងនៅក្នុងផ្នែកនេះ។

៥. តុលាការឬសាលាក្តីណាមួយដែលវិវាទត្រូវបានដាក់ជូនក្រោមផ្នែកនេះ ត្រូវស្នើអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនានានៃអនុសញ្ញានៃកិច្ចព្រមព្រៀងនេះនិងកិច្ចព្រមព្រៀងស្តីពីជលផលដែលពាក់ព័ន្ធនៅថ្នាក់តំបន់ ថ្នាក់អនុតំបន់ ឬសកលលោក ក៏ដូចជាបទដ្ឋានទូទៅដែលបានទទួលស្គាល់សម្រាប់ការអភិរក្ស និងការគ្រប់គ្រងធនធានជលផលមានជីវិតនៅក្នុងសមុទ្រនិងច្បាប់អន្តរជាតិផ្សេងៗទៀត ស្របគ្នានឹងអនុសញ្ញាដែលធានាការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយពាក់ព័ន្ធ។

## មាត្រា៣១. វិធានការបណ្តោះអាសន្ន

១. ក្នុងពេលមិនទាន់មានការដោះស្រាយវិវាទអនុលោមតាមផ្នែកនេះ ភាគីទំនាស់ត្រូវខិតខំប្រឹងប្រែងឱ្យមានការរៀបចំការអនុវត្តបណ្តោះអាសន្នជាក់ស្តែង។

២. ដោយមិនធ្វើបុរេវិនិច្ឆ័យនៃមាត្រា២៩០នៃអនុសញ្ញា តុលាការឬសាលាក្តីដែលវិវាទត្រូវបានដាក់ជូននៅក្នុងផ្នែកនេះ អាចចាត់វិធានការបណ្តោះអាសន្នណាមួយដែលខ្លួនចាត់ទុកថាសមស្របដើម្បីរក្សាការពារសិទ្ធិជូនភាគីទំនាស់ទាំងនោះ ឬដើម្បីបង្ការការខូចខាតដល់ផលស្តុកដែលកំពុងស្ថិតក្នុងភាពមិនច្បាស់លាស់ ព្រមទាំងក្នុងកាលៈទេសៈដូចដែលមានចែងក្នុងមាត្រា៧ កថាខណ្ឌទី៥ និងមាត្រា១៦ កថាខណ្ឌទី២។

៣. រដ្ឋភាគីក្នុងកិច្ចព្រមព្រៀងនេះដែលមិនមែនជាភាគីនៃអនុសញ្ញា អាចប្រកាសថាតុលាការអន្តរជាតិស្ដីពីនីតិសមុទ្រ គ្មានសិទ្ធិកែតម្រូវឬលុបចោលនូវវិធានការបណ្ដោះអាសន្នណាមួយ បើគ្មានការយល់ព្រមពីរដ្ឋភាគីទាំងនោះ ទោះជាមិនផ្អែកតាមមាត្រា២៩០នៃកថាខណ្ឌទី៥នៃអនុសញ្ញានេះក៏ដោយ។

## មាត្រា៣២. ដែនកំណត់ស្ដីពីនីតិវិធីដែលអាចអនុវត្តបានក្នុងការដោះស្រាយវិវាទ

មាត្រា២៩៧ កថាខណ្ឌទី៣នៃអនុសញ្ញាអាចអនុវត្តបានក្នុងកិច្ចព្រមព្រៀងនេះ។

# ផ្នែកទី៩. ភាគីមិនមែនជាសមាជិកក្នុងកិច្ចព្រមព្រៀង

## មាត្រា៣៣. ភាគីមិនមែនជាសមាជិកក្នុងកិច្ចព្រមព្រៀង

១. រដ្ឋភាគីត្រូវលើកទឹកចិត្តឱ្យរដ្ឋមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ ក្លាយជាភាគី និងអនុម័តច្បាប់និងបទប្បញ្ញត្តិ ដែលស្របជាមួយនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

២. រដ្ឋភាគីនានាត្រូវចាត់វិធានការស្របជាមួយនឹងកិច្ចព្រមព្រៀងនេះ និងច្បាប់អន្តរជាតិ ដើម្បីទប់ស្កាត់សកម្មភាព របស់នាវាដែលបំពាក់ទង់ជាតិរដ្ឋមិនមែនភាគីដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះ

# ផ្នែកទី១០. ការជឿទុកចិត្តនិងការរំលោភសិទ្ធិ

## មាត្រា៣៤. ការជឿទុកចិត្តនិងការរំលោភសិទ្ធិ

រដ្ឋភាគីត្រូវបំពេញកាតព្វកិច្ចដោយប្រកាន់ខ្ជាប់នូវការជឿទុកចិត្តទៅលើកិច្ចព្រមព្រៀងនេះ និងត្រូវអនុវត្តសិទ្ធិ ដែលទទួលស្គាល់នៅក្នុងកិច្ចព្រមព្រៀងនេះ ក្នុងលក្ខខណ្ឌដែលមិនបង្កើតជាបញ្ហា ដល់ការរំលោភបំពាននៃសិទ្ធិ ឡើយ។

# ផ្នែកទី១១. ភារកិច្ចនិងភាពទទួលខុសត្រូវ

## មាត្រា៣៥. ភារកិច្ចនិងភាពទទួលខុសត្រូវ

រដ្ឋភាគីគឺមានភាពទទួលខុសត្រូវអនុលោមតាមច្បាប់អន្តរជាតិ ក្នុងការបង្កការខូចខាត ឬការបាត់បង់ប្រយោជន៍ ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងនេះ។

# ផ្នែកទី១២. សន្និសីទពិនិត្យឡើងវិញ

## មាត្រា៣៦. សន្និសីទពិនិត្យឡើងវិញ

១. បួនឆ្នាំក្រោយពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះប្រជុំ សន្និសីទមួយ ក្នុងគោលបំណងវាយតម្លៃប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងនេះ ដើម្បីធានាការគ្រប់គ្រងនិងអភិរក្ស ផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ។ អគ្គលេខាធិការនឹងអញ្ជើញរដ្ឋភាគីទាំងអស់ឱ្យចូលរួម

ព្រមទាំងរដ្ឋនិងស្ថាប័នដែលនឹងមានសិទ្ធិក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះ ក៏ដូចជាអង្គការអន្តររដ្ឋា ភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលដែលមានសិទ្ធិចូលរួមជាអ្នកសង្កេតការណ៍។

២. សន្និសីទត្រូវពិនិត្យនិងវាយតម្លៃឡើងវិញនូវបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះឱ្យបានគ្រប់ជ្រុងជ្រោយ ប្រសិនបើចាំបាច់ ត្រូវស្នើសុំមធ្យោបាយក្នុងការពង្រឹងខ្លឹមសារនិងវិធីសាស្ត្រនៃការអនុវត្តបទប្បញ្ញត្តិទាំងនោះ ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការឆ្លើយតបទៅនឹងមធ្យោបាយដោះស្រាយបញ្ហាណាមួយ ដែលកំពុងបន្តកើតមាននៅក្នុងការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

## ផ្នែកទី១៣. អវសានប្បញ្ញត្តិ

### មាត្រា៣៧. ការចុះហត្ថលេខា

កិច្ចព្រមព្រៀងនេះត្រូវបានបើកចំហឱ្យចុះហត្ថលេខា ដោយរដ្ឋទាំងអស់ និងស្ថាប័នផ្សេងៗទៀតដោយអនុលោមទៅតាមមាត្រា១ កថាខណ្ឌទី២ (ខ) រួចត្រូវទុករយៈពេលសម្រាប់ចុះហត្ថលេខា នៅទីស្នាក់ការអង្គការសហប្រជាជាតិចំនួន១២ខែ គិតចាប់ពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៥។

### មាត្រា៣៨. ការផ្តល់សច្ចាប័ន

កិច្ចព្រមព្រៀងនេះនឹងត្រូវផ្តល់សច្ចាប័នដោយរដ្ឋនិងស្ថាប័នផ្សេងៗទៀតដោយអនុលោមតាមមាត្រា១កថាខណ្ឌទី២(ខ)។ លិខិតុបករណ៍នៃការផ្តល់សច្ចាប័នត្រូវតម្កល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

### មាត្រា៣៩. ការចូលជាសមាជិក

កិច្ចព្រមព្រៀងនេះនៅតែបើកចំហ សម្រាប់ការចូលជាសមាជិកពីសំណាក់រដ្ឋនិងស្ថាប័នផ្សេងៗទៀតដោយយោងទៅតាមមាត្រា១ កថាខណ្ឌទី២ (ខ)។ លិខិតុបករណ៍នៃការចូលបន្ថែមត្រូវតម្កល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

### មាត្រា៤០. ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានរយៈពេល៣០ថ្ងៃ ក្រោយពីថ្ងៃដាក់តម្កល់លិខិតុបករណ៍ទី៣០ នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក។

២. សម្រាប់រដ្ឋនិងស្ថាប័នដែលផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឬចូលជាសមាជិកក្រោយពីការតម្កល់លិខិតុបករណ៍ទី៣០ ការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាននៅ៣០ថ្ងៃក្រោយពីការដាក់តម្កល់លិខិតុបករណ៍ផ្តល់សច្ចាប័នឬការចូលជាសមាជិកនោះ។

### មាត្រា៤១. ការអនុវត្តបណ្តោះអាសន្ន

១. កិច្ចព្រមព្រៀងនេះ ត្រូវបានអនុវត្តជាបណ្តោះអាសន្នដោយរដ្ឋ ឬស្ថាប័នដែលបានយល់ព្រមអនុវត្តជាបណ្តោះអាសន្ន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់អ្នកទទួលបន្ទុករក្សាទុកតម្កល់ឯកសារ។ ការអនុវត្តបណ្តោះអាសន្ននោះត្រូវមានសុពលភាពចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងនោះ។

២. ការអនុវត្តជាបណ្តោះអាសន្នដោយរដ្ឋ ឬស្ថាប័នត្រូវបញ្ចប់ នៅពេលកិច្ចព្រមព្រៀងចូលជាធរមានសម្រាប់រដ្ឋឬស្ថាប័ន ឬអាស្រ័យលើការជូនដំណឹងរបស់រដ្ឋ ឬស្ថាប័នជាលាយលក្ខណ៍អក្សរស្តីពីការបញ្ចប់ការអនុវត្តជាបណ្តោះអាសន្នរបស់ខ្លួន ទៅកាន់អ្នកទទួលបន្ទុកតម្កល់ឯកសារ។

### មាត្រា៤២. ការបម្រុងទុកនិងការលើកលែង

គ្មានការបម្រុងទុកនិងការលើកលែងណាមួយដែលត្រូវបានធ្វើឡើងក្នុងកិច្ចព្រមព្រៀងនេះទេ។

### មាត្រា៤៣. សេចក្តីប្រកាសនិងសេចក្តីថ្លែងការណ៍

មាត្រា៤២មិនរារាំងរដ្ឋឬស្ថាប័ន នៅពេលចុះហត្ថលេខាផ្តល់សច្ចាប័នឬយល់ព្រមលើកិច្ចព្រមព្រៀងនេះ មិនឱ្យធ្វើសេចក្តីប្រកាសឬសេចក្តីថ្លែងការណ៍ ទោះបីជាការដាក់ប្រយោគឬឈ្មោះឱ្យស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួនទៅនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវផ្តល់នូវការបញ្ជាក់ក្នុងសេចក្តីប្រកាសឬសេចក្តីថ្លែងការណ៍ថាមិនសំដៅដល់ការដកចេញឬកែប្រែភាពស្របច្បាប់របស់បទប្បញ្ញត្តិរបស់កិច្ចព្រមព្រៀងនេះក្នុងការអនុវត្តរបស់រដ្ឋឬស្ថាប័ននោះឡើយ

### មាត្រា៤៤. ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងផ្សេងទៀត

១. កិច្ចព្រមព្រៀងនេះ នឹងមិនកែប្រែសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋភាគី ដែលមានចែងក្នុងកិច្ចព្រមព្រៀងផ្សេងទៀតសមស្របជាមួយកិច្ចព្រមព្រៀងនេះ និងមិនប៉ះពាល់ដល់ផលប្រយោជន៍របស់រដ្ឋភាគីផ្សេងទៀតដែលសិទ្ធិឬការអនុវត្តកាតព្វកិច្ចរបស់ពួកគេស្ថិតក្រោមកិច្ចព្រមព្រៀងនេះ។
២. រដ្ឋភាគីចំនួនពីរ ឬច្រើនអាចសម្រេចកែប្រែកិច្ចព្រមព្រៀង ឬផ្អាកប្រតិបត្តិជាបណ្តោះអាសន្ននូវបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ អាចអនុវត្តតែម្នាក់ឯងចំពោះទំនាក់ទំនងរវាងពួកគេដែលបានផ្តល់នូវកិច្ចព្រមព្រៀងទាំងនោះជាបណ្តោះ អាសន្ន ដែលមិនពាក់ព័ន្ធនឹងបទប្បញ្ញត្តិពីអ្វីដែលមិនសមស្របនឹងគោលបំណងនិងគោលដៅនៃការអនុវត្តកិច្ចព្រមព្រៀងនេះប្រកបដោយប្រសិទ្ធភាព និងបានផ្តល់បន្ថែមទៀតលើកិច្ចព្រមព្រៀងនេះថាវានឹងមិនប៉ះពាល់ដល់ការអនុវត្តគោលការណ៍មូលដ្ឋានដែលមាននៅទីនេះ ហើយបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងទាំងនេះមិនប៉ះពាល់ដល់ផលប្រយោជន៍របស់រដ្ឋភាគីផ្សេងទៀត ឬការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ។
៣. រដ្ឋភាគីដែលមានបំណងដើម្បីបញ្ចប់កិច្ចព្រមព្រៀង ដោយយោងតាមកថាខណ្ឌទី២ ត្រូវជូនដំណឹងពីគោលបំណងរបស់គេដល់រដ្ឋភាគីផ្សេងទៀត តាមរយៈអ្នកទទួលបន្ទុកតម្កល់ទុកកិច្ចព្រមព្រៀងដើម្បីបញ្ចប់កិច្ចព្រមព្រៀង កែប្រែ ឬការផ្អាកនូវអ្វីដែលបានដាក់ជូន។

### មាត្រា៤៥. វិសោធនកម្ម

១. រដ្ឋភាគីមួយអាចទាក់ទងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយសរសេរជាលាយលក្ខណ៍អក្សរដើម្បីស្នើសុំធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ និងស្នើសុំឱ្យកោះប្រជុំសន្និសីទ ដើម្បីពិចារណាលើការធ្វើសំណើវិសោធនកម្មនេះ។ អគ្គលេខាធិការត្រូវផ្សព្វផ្សាយលិខិតស្នើសុំនេះទៅកាន់រដ្ឋភាគីទាំងអស់។ ប្រសិនបើក្នុងរយៈពេល៦ខែ ចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយលិខិតស្នើសុំនេះ រដ្ឋភាគីច្រើនជាងពាក់កណ្តាលពេញចិត្តឆ្លើយតបទៅនឹងសំណើនេះ អគ្គលេខាធិការត្រូវកោះប្រជុំសន្និសីទ។

២. នីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្តធ្វើវិសោធនកម្មអាចអនុវត្តបាន នៅក្នុងសន្និសីទតាមរយៈការកោះប្រជុំ ដោយអនុលោមទៅតាមកថាខណ្ឌទី១ ហើយត្រូវអនុវត្តដូចគ្នានៅក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពីផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ បើមិនដូច្នេះទេ នីតិវិធីធ្វើវិសោធនកម្មត្រូវសម្រេចដោយសន្និសីទនេះ។ សន្និសីទនេះគួរតែខិតខំប្រឹងប្រែងដើម្បីសម្រេចកិច្ចព្រមព្រៀងលើការធ្វើវិសោធនកម្មណាមួយ ដោយការមូលមតិគ្នាជាឯកឆន្ទនិងមិនគួរមានការបោះឆ្នោតធ្វើវិសោធកម្មទៅលើកិច្ចព្រមព្រៀង រហូតទាល់តែកិច្ចខិតខំប្រឹងប្រែងបញ្ចុះបញ្ចូលត្រូវបានធ្វើឡើងដោយអស់លទ្ធភាព។

៣. នៅពេលដែលបានអនុម័តហើយ វិសោធនកម្មកិច្ចព្រមព្រៀងនេះត្រូវបើកចំហសម្រាប់ការចុះហត្ថលេខាដោយរដ្ឋភាគីទាំងអស់នៅឯទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ ក្នុងរយៈពេល១២ខែគិតចាប់ពីកាលបរិច្ឆេទនៃការអនុម័តនេះ លើកលែងតែមានចែងផ្ទុយពីនេះ នៅក្នុងវិសោធនកម្មនោះ។

៤. មាត្រា៣៨ មាត្រា៣៩ មាត្រា៤៧ និងមាត្រា៥០ ត្រូវអនុវត្តចំពោះការធ្វើវិសោធនកម្មទាំងអស់ក្នុងកិច្ចព្រមព្រៀងនេះ។

៥. វិសោធនកម្មកិច្ចព្រមព្រៀងនេះនឹងចូលជាធរមានសម្រាប់រដ្ឋភាគីផ្តល់សច្ចាប័ន ឬផ្តល់សុពលភាពដល់ការធ្វើវិសោធនកម្មនោះនៅ៣០ថ្ងៃក្រោយ គិតចាប់ពីថ្ងៃដាក់តម្កល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដោយរដ្ឋភាគីសមាជិកចំនួនពីរភាគបី (២/៣)។ បន្ទាប់មក រដ្ឋដែលផ្តល់សច្ចាប័នឬចូលជាសមាជិកត្រូវចូលជាធរមាននៅ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់តម្កល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬចូលជាសមាជិក។

៦. ការធ្វើវិសោធនកម្មតិចឬច្រើន គឺអាចផ្តល់ឱ្យភាគីពាក់ព័ន្ធចូលរួមផ្តល់សច្ចាប័នឬការចូលរួមជាសមាជិក ជាជាងការតម្រូវនៅក្នុងមាត្រានេះ។

៧. រដ្ឋដែលនឹងក្លាយជាសមាជិករបស់កិច្ចព្រមព្រៀងនេះ បន្ទាប់ពីការធ្វើវិសោធនកម្មចូលជាធរមានដោយស្របតាមកថាខណ្ឌទី៥ នៅពេលបរាជ័យក្នុងការបង្ហាញឆន្ទៈ មិនឯកភាពក្នុងការធ្វើវិសោធនកម្មនេះត្រូវ៖

   (ក) បានចាត់ទុកថាជាសមាជិកក្នុងកិច្ចព្រមព្រៀងនេះ ដូចដែលបានធ្វើវិសោធនកម្ម។

   (ខ) បានចាត់ទុកថាជាសមាជិកក្នុងកិច្ចព្រមព្រៀងដែលមិនបានធ្វើវិសោធនកម្ម ក្នុងនាមជារដ្ឋភាគីដែលមិនស្ថិតក្រោមកិច្ចព្រមព្រៀងដែលបានធ្វើវិសោធកម្មនោះទេ។

## មាត្រា៤៦. ការប្តឹងជំទាស់

១. រដ្ឋភាគីអាចសរសេរជាលាយលក្ខណ៍អក្សរជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ប្រកាសពីការមិនឯកភាពលើកិច្ចព្រមព្រៀងនេះ និងអាចបង្ហាញពីហេតុផលរបស់ខ្លួន។ ការបរាជ័យក្នុងការចង្អុលបង្ហាញពីហេតុផលនឹងមិនប៉ះពាល់ដល់សុពលភាពនៃការប្តឹងជំទាស់នោះទេ។ ការប្តឹងជំទាស់នេះនឹងមានប្រសិទ្ធភាពមួយឆ្នាំ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងនេះ លើកលែងតែមានការបញ្ជាក់ក្នុងសេចក្តីជូនដំណឹងនៅពេលក្រោយ

២. ការប្តឹងជំទាស់នេះនឹងមិនប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋភាគីណាមួយ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ លើកលែងតែជាប្រធានបទដាច់ដោយឡែកនៅក្រោមច្បាប់អន្តរជាតិ។

## មាត្រា៤៧.ការចូលរួមដោយអង្គការអន្តរជាតិ

១. ក្នុងករណីអង្គការអន្តរជាតិមួយដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៩មាត្រា១ នៃអនុសញ្ញានេះមិនមានសមត្ថកិច្ចគ្របដណ្តប់លើគ្រប់បញ្ហាទាំងអស់ក្នុងកិច្ចព្រមព្រៀងនេះ ប៉ុន្តែយោងតាមឧបសម្ព័ន្ធទី៩នៃអនុសញ្ញា ត្រូវអនុវត្តតាម

ជម្រើសដូចគ្នាដោយមិនកែប្រែន័យដើម ដើម្បីចូលរួមជាមួយអង្គការអន្តរជាតិ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ លើកលែងតែបទប្បញ្ញត្តិនៃឧបសម្ព័ន្ធខាងក្រោមមិនត្រូវបានអនុវត្ត៖

(ក) មាត្រា២ក្នុងឃ្លាទី១

(ខ) មាត្រា៣ក្នុងកថាខណ្ឌទី១។

២. ក្នុងករណីអង្គការអន្តរជាតិមួយ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៩ មាត្រា១នៃអនុសញ្ញាមានសមត្ថកិច្ចគ្របដណ្តប់លើគ្រប់បញ្ហាក្នុងកិច្ចព្រមព្រៀងនេះ បទប្បញ្ញត្តិដូចខាងក្រោមនេះត្រូវអនុវត្តចំពោះការចូលរួមដោយអង្គការអន្តរជាតិដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ៖

(ក) នៅពេលចុះហត្ថលេខាឬការចូលជាសមាជិកបន្ថែម អង្គការអន្តរជាតិនេះត្រូវធ្វើសេចក្តីប្រកាសដូចខាងក្រោម៖

(i) មានសមត្ថកិច្ចគ្របដណ្តប់លើគ្រប់បញ្ហាទាំងអស់ ដែលបានកំណត់ដោយកិច្ចព្រមព្រៀងនេះ

(ii) សម្រាប់ហេតុផលនេះ រដ្ឋជាសមាជិករបស់អង្គការនេះ មិនត្រូវក្លាយជារដ្ឋភាគី លើកលែងតែបានគោរពបូរណភាពទឹកដីរបស់ខ្លួននៅពេលដែលអង្គការអន្តរជាតិមិនអាចទទួលខុសត្រូវ

(iii) សុខចិត្តទទួលយកសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋនៅក្រោមកិច្ចព្រមព្រៀងនេះ។

(ខ) ការចូលរួមរបស់អង្គការអន្តរជាតិ ទោះក្នុងករណីណាមួយក៏ដោយនៅក្រោមកិច្ចព្រមព្រៀងនេះ ក៏គ្មានសិទ្ធិត្រួតត្រាលើរដ្ឋជាសមាជិកនៃអង្គការអន្តរជាតិនេះបានឡើយ

(គ) ក្នុងករណីមានវិវាទរវាងកាតព្វកិច្ចរបស់អង្គការអន្តរជាតិ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ និងកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងបង្កើតអង្គការអន្តរជាតិនោះឡើង ឬសកម្មភាពពាក់ព័ន្ធណាមួយកាតព្វកិច្ចនានាដែលផ្ទុយពីកិច្ចព្រមព្រៀងនេះនឹងត្រូវទុកជានិរាករណ៍។

## មាត្រា៤៨. ឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធទាំងអស់បង្កើតជាផ្នែកនៃកិច្ចព្រមព្រៀង ហើយរាល់ការប្រើជាឯកសារយោងត្រូវមានភ្ជាប់ជាមួយឧបសម្ព័ន្ធទាំងនេះ។

២. ឧបសម្ព័ន្ធទាំងនេះអាចនឹងត្រូវបានកែសម្រួលពីពេលវេលាមួយទៅពេលវេលាមួយទៀតដោយរដ្ឋភាគី។ ការកែសម្រួលនេះត្រូវផ្អែកលើការពិចារណាតាមបែបវិទ្យាសាស្ត្រនិងបច្ចេកទេស។ ដោយមិនយោងតាមបទប្បញ្ញត្តិនៃមាត្រា៤៥ ការកែសម្រួលក្នុងឧបសម្ព័ន្ធត្រូវបានអនុម័តដោយកុងសង់ស៊ុសនៅក្នុងកិច្ចប្រជុំរបស់រដ្ឋភាគី ហើយនឹងត្រូវបានដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងនេះ និងមានសុពលភាពដោយគិតចាប់ពីថ្ងៃខែបានអនុម័តឬតាមកាលបរិច្ឆេទផ្សេងទៀតដែលបានឯកភាពក្នុងពេលកែសម្រួលឡើងវិញ។ ប្រសិនបើការកែសម្រួលក្នុងឧបសម្ព័ន្ធមិនត្រូវបានអនុម័តដោយកុងសង់ស៊ុសនៅក្នុងកិច្ចប្រជុំនោះទេ នីតិវិធីធ្វើវិសោធនកម្មមាត្រា៤៥អាចយកទៅអនុវត្តបាន។

## មាត្រា៤៩.អ្នកតម្កល់ឯកសារ

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ គឺជាអ្នកទទួលបន្ទុកតម្កល់ឯកសារកិច្ចព្រមព្រៀងនេះ និងការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងឬកំណែសម្រួលបន្ថែមណាមួយ។

**មាត្រា៥០.យថាភូតភាពនៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជាជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានភាពស្របច្បាប់ដូចគ្នា។

ជាសក្ខីភាព ឯកអគ្គរដ្ឋទូតពេញសមត្ថភាព មានសមត្ថកិច្ចស្របច្បាប់លើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

បើកឱ្យចុះហត្ថលេខានៅទីក្រុងញូវយ៉ក នាថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៥ គឺជាឯកសារដើមតែមួយគត់ជាភាសាអារ៉ាប់ អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល។

## ឧបសម្ព័ន្ធទី១.គម្រូខការស្តង់ដារសម្រាប់ការប្រមូលនិងការចែករំលែកទិន្នន័យ

### មាត្រា១. គោលការណ៍ទូទៅ

១. ការប្រមូល ការចងក្រង និងការវិភាគទិន្នន័យបានទាន់ពេលវេលា គឺជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងនិងអភិរក្សប្រកបដោយប្រសិទ្ធភាព សម្រាប់ផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ។ ដើម្បីសម្រេចគោលដៅនេះ ទិន្នន័យជលផលពីផលស្តុកត្រីនៅតំបន់សមុទ្រអន្តរជាតិនិងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិគឺតម្រូវឱ្យមាននិងគួរតែត្រូវបានប្រមូលនិងចងក្រងតាមវិធីសាស្រ្តមួយ ដែលមានទិន្នន័យគ្រប់គ្រាន់សម្រាប់ការវិភាគស្ថិតិ ក្នុងគោលបំណងនៃការគ្រប់គ្រងនិងអភិរក្សធនធានជលផល។ ទិន្នន័យទាំងនោះរួមមានទិន្នន័យពីផលនេសាទដែលចាប់បាន និងស្ថិតិពីសមត្ថភាពនេសាទ ព្រមទាំងព័ត៌មានពាក់ព័ន្ធជលផលផ្សេងទៀត ដូចជាស្ថិតិពាក់ព័ន្ធនឹងនាវានេសាទ និងទិន្នន័យផ្សេងទៀត សម្រាប់ធ្វើឱ្យសមត្ថភាពនេសាទបានតាមស្តង់ដារ។ ទិន្នន័យដែលប្រមូលបានគួរមានដូចជា ព័ត៌មានអំពីផលនេសាទ ប្រភេទមិនមែនគោលដៅ និងប្រភេទពាក់ព័ន្ធឬពឹងអាស្រ័យ។ គ្រប់ព័ត៌មានទាំងអស់ត្រូវតែមានការផ្ទៀងផ្ទាត់ច្បាស់លាស់ ដើម្បីធានាពីភាពពិតប្រាកដរបស់វា។ ទិន្នន័យមិនទាន់គ្រប់គ្រាន់នឹងត្រូវបានរក្សាទុកជាការសម្ងាត់។ ការចែកចាយទិន្នន័យបែបនេះ គឺជាកម្មវត្ថុនៃលក្ខខណ្ឌដែលបានកំណត់។

២. ជំនួយរួមមានការបណ្តុះបណ្តាល ក៏ដូចជាជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស ត្រូវតែផ្តល់ឱ្យទៅប្រទេសកំពុងអភិវឌ្ឍក្នុងគោលបំណងដើម្បីកសាងសមត្ថភាពក្នុងការគ្រប់គ្រងនិងអភិរក្សធនធានសមុទ្រមានជីវិត។ ជំនួយទាំងនោះត្រូវផ្តោតលើការលើកកម្ពស់សមត្ថភាព ក្នុងការអនុវត្តប្រមូលទិន្នន័យ និងការផ្ទៀងផ្ទាត់ទិន្នន័យ កម្មវិធីអ្នកសង្កេតការណ៍ ការវិភាគទិន្នន័យ និងការគាំទ្រក្នុងគម្រោងវាយតម្លៃផលស្តុក។ ការចូលរួមយ៉ាងពេញលេញរបស់អ្នកវិទ្យាសាស្រ្ត និងអ្នកគ្រប់គ្រងដែលស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍទៅលើការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម ឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ គួរត្រូវបានលើកកម្ពស់។

### មាត្រា២. គោលការណ៍នៃការប្រមូល ការចងក្រង និងការផ្លាស់ប្តូរទិន្នន័យ

គោលការណ៍ទូទៅខាងក្រោមគួរត្រូវបានពិចារណានៅក្នុងការកំណត់ប៉ារ៉ាម៉ែត្រសម្រាប់ការប្រមូលការចងក្រងនិងការផ្លាស់ប្តូរទិន្នន័យពីការធ្វើនេសាទផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ៖

(ក) រដ្ឋនានាត្រូវធានាថា ទិន្នន័យដែលប្រមូលបានពីនាវានេសាទបំពាក់ទង់ជាតិរបស់ខ្លួន ពីសកម្មភាពនេសាទដោយយោងទៅតាមលក្ខណៈនៃការធ្វើនេសាទ តាមវិធីសាស្រ្តនីមួយៗ (ឧទាហរណ៍៖ អួនអូសសន្ទូចរនង និងអួនទិត ហ្វូងត្រីដែលនេសាទបានដោយស្ទូនិងសន្ទូច និងការនេសាទរាល់ថ្ងៃដោយសន្ទូចអូស) និងមានព័ត៌មានលម្អិតគ្រប់គ្រាន់ដើម្បីជួយសម្រួលដល់ការវាយតម្លៃផលស្តុកប្រកបដោយប្រសិទ្ធភាព

(ខ) រដ្ឋនានាត្រូវធានាថាទិន្នន័យផលនេសាទត្រូវបានផ្ទៀងផ្ទាត់តាមប្រព័ន្ធសមស្របមួយ

(គ) រដ្ឋនានាត្រូវចងក្រងទិន្នន័យដែលពាក់ព័ន្ធនឹងការនេសាទ និងទិន្នន័យគាំទ្រផ្នែកវិទ្យាសាស្រ្តផ្សេងទៀត និងត្រូវផ្តល់ទិន្នន័យតាមទម្រង់ព្រមព្រៀង និងទាន់ពេលវេលាដល់អង្គការ ឬក្រុមការងារគ្រប់គ្រងជលផលពាក់ព័ន្ធថ្នាក់តំបន់ឬអនុតំបន់ដែលមានវត្តមាននៅទីនោះ។ បើមិនដូច្នោះទេ រដ្ឋនានាគួរតែសហការគ្នាដើម្បីផ្លាស់ប្តូរទិន្នន័យដោយផ្ទាល់ ឬតាមរយៈយន្តការកិច្ចសហប្រតិបត្តិការផ្សេងទៀតណាមួយក៏បាន ដូចដែលបានព្រមព្រៀងជាមួយគ្នា

(ឃ) រដ្ឋនានាត្រូវឯកភាពគ្នានៅក្នុងក្របខ័ណ្ឌនៃអង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ ឬបើមិនដូច្នោះទេ នៅលើការបញ្ជាក់ទិន្នន័យនិងទម្រង់ទិន្នន័យដែលត្រូវផ្តល់ជូនដោយអនុលោមតាម ឧបសម្ព័ន្ធនេះ និងដោយពិចារណាលើធម្មជាតិរបស់ផលស្តុក និងផលស្តុកជលផលនៅក្នុងតំបន់។ អង្គការឬក្រុមការងារនេះគួរស្នើសុំរដ្ឋដែលមិនមែនជាសមាជិក ឬអ្នកដែលមិនមែនជាអ្នកចូលរួម ឱ្យជួយផ្តល់ទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពនេសាទរបស់នាវាបំពាក់ទង់ជាតិរបស់ខ្លួន

(ង) អង្គការឬក្រុមការងារនេះ ត្រូវរៀបចំចងក្រងទិន្នន័យដែលងាយស្រួលរកបានគ្រប់ពេល និងនៅក្នុងទម្រង់ដែលបានឯកភាពគ្នា ដើម្បីផ្តល់ឱ្យរដ្ឋដែលមានការពាក់ព័ន្ធនៅក្នុងលក្ខខណ្ឌ និងពេលវេលាដែលបានកំណត់ឡើងដោយអង្គការឬក្រុមការងារនោះ

(ច) អ្នកវិទ្យាសាស្ត្ររបស់រដ្ឋម្ចាស់ទង់ជាតិនិងអ្នកមកពីអង្គការឬក្រុមការងារគ្រប់គ្រងធនធានជលផលថ្នាក់តំបន់និងអនុតំបន់ គួរវិភាគទិន្នន័យដោយឡែកឬរួមគ្នាតាមលក្ខណៈដែលសមស្របបំផុត។

## មាត្រា៣. ទិន្នន័យជលផលជាមូលដ្ឋាន

១. រដ្ឋនានាត្រូវប្រមូលនិងផ្តល់ទិន្នន័យឱ្យអង្គការឬក្រុមការងារគ្រប់គ្រងធនធានជលផលថ្នាក់តំបន់និងអនុតំបន់ដែលបានបង្កើតឡើងនូវប្រភេទទិន្នន័យលម្អិត ដើម្បីវាយតម្លៃផលស្តុកប្រកបដោយប្រសិទ្ធភាពស្របតាមនីតិវិធីដែលបានឯកភាពគ្នាដូចខាងក្រោម៖

(ក) តារាងស្ថិតិផលនេសាទនិងឧបករណ៍នេសាទតាមរដូវនេសាទ ប្រភេទឧបករណ៍និងតាមប្រភេទនាវានេសាទ

(ខ) ផលនេសាទសរុបគិតជាចំនួន ទម្ងន់ ឬទិន្នន័យទាំងពីរនេះ ដោយបែងចែកតាមប្រភេទផលនេសាទ (ប្រភេទគោលដៅនិងមិនមែនគោលដៅ) ឱ្យសមស្របតាមប្រភេទផលនេសាទនីមួយៗ។ ទម្ងន់ប៉ាន់ស្មានផលនេសាទសរុប គឺស្មើនឹងទម្ងន់ប៉ាន់ស្មានផលនេសាទស្រស់សរុបដែលផ្ទេរនៅលើផែនេសាទ ដែលបានកំណត់ដោយអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ

(គ) ស្ថិតិផលនេសាទដែលបោះបង់ចោល រួមបញ្ចូលផលនេសាទដែលប៉ាន់ស្មានគិតជាចំនួនឬទម្ងន់តាមប្រភេទត្រីដែលជាតម្រូវការក្នុងការប្រមូលទិន្នន័យក្នុងវិស័យជលផល

(ឃ) ស្ថិតិនៃប្រសិទ្ធភាពនេសាទសមស្របទៅនឹងវិធីសាស្ត្រនេសាទនីមួយៗ

(ង) ទីតាំង កាលបរិច្ឆេទ និងពេលវេលានៃការនេសាទ និងស្ថិតិផ្សេងទៀតនៅពេលធ្វើនេសាទតាមការចាំបាច់។

២. រដ្ឋនានាត្រូវប្រមូលផងដែរនូវព័ត៌មានតាមការចាំបាច់ផ្តល់ឱ្យអង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ ឬអនុតំបន់ ដើម្បីគាំទ្រដល់ការវាយតម្លៃផលស្តុករួមមាន៖

(ក) សមាសភាគនៃផលនេសាទគិតតាមប្រវែង ទម្ងន់ និងភេទ

(ខ) ព័ត៌មានជីវសាស្ត្រដទៃទៀតដែលគាំទ្រដល់ការវាយតម្លៃផលស្តុកដូចជា អាយុ ការលូតលាស់ កំណើន របាយកន្លែងរស់នៅ និងអត្តសញ្ញាណផលស្តុក

(គ) ការស្រាវជ្រាវពាក់ព័ន្ធផ្សេងទៀត រួមទាំងការស្រាវជ្រាវពីភាពសម្បូរ ជីវម៉ាស់ រលកសំឡេងក្នុងទឹក កត្តាបរិស្ថានដែលប៉ះពាល់ដល់ភាពសម្បូរបែបនៃផលស្តុក និងការសិក្សាពីភូមិសាស្ត្រ សាគរសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ី។

## មាត្រា៤. ទិន្នន័យនិងព័ត៌មាននាវានេសាទ

១. រដ្ឋនានាត្រូវប្រមូលទិន្នន័យដែលទាក់ទងនឹងនាវានេសាទ សម្រាប់ធ្វើបទដ្ឋានសមាសភាពក្រុមនាវា និងកម្លាំងនេសាទរបស់នាវា និងសម្រាប់ការបម្លែងរវាងរង្វាស់នៃកម្លាំងនេសាទផ្សេងៗ ក្នុងការវិភាគទិន្នន័យនៃផលចាប់ និងឧបករណ៍នេសាទ៖

   (ក) អត្តសញ្ញាណនាវានេសាទ ទង់ជាតិ និងកំពង់ផែនេសាទដែលបានចុះបញ្ជី

   (ខ) ប្រភេទនាវានេសាទ

   (គ) ការកំណត់ទំហំនាវានេសាទ (ឧទាហរណ៍៖ សម្ភារៈក្នុងការសាងសង់ កាលបរិច្ឆេទនៃការសាងសង់ ប្រវែង និងចំណុះចុះបញ្ជី កម្លាំងម៉ាស៊ីនសំខាន់ ចំណុះផ្ទុក និងវិធីសាស្ត្រក្នុងការរក្សាផលនេសាទ)

   (ឃ) ការរៀបរាប់អំពីឧបករណ៍នេសាទ (ឧទាហរណ៍៖ ប្រភេទ ធាតុផ្សំក្នុងការផលិត និងចំនួនឧបករណ៍នេសាទ)។

២. រដ្ឋម្ចាស់ទង់ជាតិត្រូវប្រមូលទិន្នន័យដូចតទៅ៖

   (ក) ឧបករណ៍ជំនួយកំណត់ទីតាំងនិងនាវាចរណ៍

   (ខ) ឧបករណ៍ទំនាក់ទំនងនិងវិទ្យុផ្តល់សញ្ញាអន្តរជាតិ

   (គ) ចំនួននាវិក។

## មាត្រា៥. ការរាយការណ៍

រដ្ឋនីមួយៗត្រូវធានាថានាវានេសាទបំពាក់ទង់ជាតិរបស់ខ្លួន ផ្ញើរបាយការណ៍ទៅកាន់រដ្ឋបាលជលផលថ្នាក់ជាតិ ហើយប្រសិនបើមានការព្រមព្រៀងគ្នា ត្រូវផ្ញើសៀវភៅកត់ត្រាទិន្នន័យផលនេសាទនិងប្រសិទ្ធភាពនេសាទ ដោយរួមបញ្ចូលទាំងទិន្នន័យនេសាទត្រីនៅដែនសមុទ្រអន្តរជាតិ ដែលមានព័ត៌មានគ្រប់គ្រាន់និងទៀងទាត់ ដើម្បីបំពេញតម្រូវការថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ និងទៅកាន់អង្គការឬក្រុមការងារគ្រប់គ្រងធនធានជលផលថ្នាក់តំបន់ឬអនុតំបន់។ ទិន្នន័យទាំងនេះនឹងត្រូវបញ្ជូនតាមការចាំបាច់តាមវិទ្យុទាក់ទង ទូរលេខ ទូរសារ ឬការបញ្ជូនតាមផ្កាយរណប ឬតាមមធ្យោបាយ ផ្សេងៗទៀត។

## មាត្រា៦. ការផ្ទៀងផ្ទាត់ទិន្នន័យ

រដ្ឋនានា ឬអង្គការ ឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ត្រូវរៀបចំយន្តការសម្រាប់ផ្ទៀងផ្ទាត់ទិន្នន័យជលផលដូចជា៖

   (ក) ការផ្ទៀងផ្ទាត់ទីតាំងនាវាតាមរយៈប្រព័ន្ធតាមដាន

   (ខ) កម្មវិធីអ្នកសង្កេតការណ៍ ដើម្បីតាមដានត្រួតពិនិត្យផលនេសាទ ប្រសិទ្ធភាពនេសាទ និងសមាសភាគផលនេសាទ(ប្រភេទគោលដៅនិងមិនមែនគោលដៅ) និងសេចក្តីលម្អិតផ្សេងទៀតនៃការធ្វើនេសាទ

   (គ) ដំណើរគន្លងរបស់នាវា ការសំចត និងរបាយការណ៍ផ្ទេរទំនិញ

   (ឃ) សំណាកពីកំពង់ផែ។

## មាត្រា៧. ការផ្លាស់ប្តូរទិន្នន័យ

១. ទិន្នន័យដែលប្រមូលដោយរដ្ឋម្ចាស់ទង់ជាតិត្រូវតែចែករំលែកជាមួយរដ្ឋម្ចាស់ទង់ជាតិដទៃទៀត និងរដ្ឋម្ចាស់ឆ្នេរតាមរយៈអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ពាក់ព័ន្ធ។ អង្គការឬក្រុមការងារទាំងនេះត្រូវរៀបចំចងក្រងទិន្នន័យនិងចែករំលែកឱ្យបានទៀងទាត់និងតាមទម្រង់ដែលបានឯកភាពគ្នា ដល់ប្រទេសនានា

ដែលពាក់ព័ន្ធនៅក្នុងលក្ខខណ្ឌឯកភាពដែលបានបង្កើតឡើងដោយអង្គការ ឬក្រុមការងារនោះ ខណៈដែលការថែរក្សាភាពសម្ងាត់របស់ទិន្នន័យដើម និងគួរពង្រីកវិសាលភាពតាមដែលអាចធ្វើបានដោយត្រូវអភិវឌ្ឍប្រព័ន្ធមូលដ្ឋានទិន្នន័យ ដែលអាចផ្តល់លទ្ធភាពទាញយកទិន្នន័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ចំពោះក្រុមពាក់ព័ន្ធដែលបានឯកភាព។

២. នៅកម្រិតសកលលោក ការប្រមូលនិងផ្សព្វផ្សាយទិន្នន័យគួរត្រូវបានអនុវត្តតាមរយៈអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ។ នៅកន្លែងដែលមិនទាន់មានអង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់ឬអនុតំបន់ អង្គការនោះនឹងធ្វើដូចគ្នានៅថ្នាក់តំបន់ឬអនុតំបន់ជាមួយប្រទេសពាក់ព័ន្ធទាំងនោះ។

**ឧបសម្ព័ន្ធទី២. គោលការណ៍ណែនាំសម្រាប់អនុវត្តអតិក្រមប្រុងប្រយ័ត្នជាមុន ក្នុងការគ្រប់គ្រង និងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ**

១. អតិក្រមប្រុងប្រយ័ត្នជាមុន គឺជាបរិមាណប៉ាន់ស្មានដែលបានមកពីវិធីសាស្ត្រវិទ្យាសាស្ត្រដោយ ព្រមព្រៀងគ្នា ឆ្លើយតបទៅនឹងស្ថានភាពរបស់ធនធាននិងការធ្វើនេសាទ ហើយដែលអាចត្រូវបានប្រើជាគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងជលផល។

២. អតិក្រមប្រុងប្រយ័ត្នជាមុន២ប្រភេទត្រូវបានគេប្រើ គឺការអភិរក្សឬដែនកំណត់អតិក្រមប្រុងប្រយ័ត្នជាមុននៃចំណុចគោល និងការគ្រប់គ្រង ឬគោលដៅអតិក្រមប្រុងប្រយ័ត្នជាមុននៃចំណុចគោល។ ចំណុចគោលដែលមានដែនកំណត់ គឺការកំណត់តំបន់នេសាទក្នុងគោលបំណងដើម្បីហាមឃាត់ការធ្វើនេសាទនៅក្នុងតំបន់សុវត្ថិភាពជីវសាស្ត្រកំណត់មួយដែលផលស្តុកអាចផ្តល់ទិន្នផលអតិបរមាប្រកបដោយនិរន្តរភាព។ ចំណុចគោលរបស់គោលដៅត្រូវបានរៀបចំទុកដើម្បីបំពេញតាមគោលបំណងក្នុងការគ្រប់គ្រង។

៣. ចំណុចគោលនៃអតិក្រមប្រុងប្រយ័ត្នជាមុន គឺជាផលស្តុកជាក់លាក់មួយដែលគិតគូអំពីសមត្ថភាពបន្តពូជ ភាពធន់ទ្រាំរបស់ផលស្តុកនីមួយៗ លក្ខណៈនៃអាជីវកម្មនេសាទលើផលស្តុក ក៏ដូចជាប្រភពអត្រាបាត់បង់និងប្រភពមិនច្បាស់លាស់មួយចំនួនធំទៀត។

៤. យុទ្ធសាស្ត្រគ្រប់គ្រង ត្រូវខំថែរក្សាឬស្តារឡើងវិញនូវបរិមាណផលស្តុកដែលបាននេសាទ និងជាពិសេស ប្រភេទដែលពាក់ព័ន្ធឬមិនមែនគោលដៅ នៅក្នុងកម្រិតសមស្របតាមចំណុចគោលនៃអតិក្រមប្រុងប្រយ័ត្នជាមុនដែលបានព្រមព្រៀងគ្នា។ ចំណុចគោលនៃអតិក្រមប្រុងប្រយ័ត្នជាមុននេះត្រូវបានប្រើប្រាស់ជាកត្តាជំរុញការឯកភាពជាមុនសម្រាប់សកម្មភាពគ្រប់គ្រងនិងអភិរក្ស។ យុទ្ធសាស្ត្រគ្រប់គ្រងត្រូវបញ្ចូលនូវវិធានការដែលអាចអនុវត្តបាន នៅពេលដែលចំណុចតម្លៃគោលនៃអតិក្រមប្រុងប្រយ័ត្នជាមុនកំពុងខិតជិតដល់។

៥. យុទ្ធសាស្ត្រគ្រប់គ្រងជលផល ត្រូវធានាថាហានិភ័យនៃការនេសាទលើសពីដែនកំណត់នៃចំណុចគោលនៃអតិក្រមប្រុងប្រយ័ត្នជាមុន គឺមានតិចតួចបំផុត។ ប្រសិនបើផលស្តុកធ្លាក់ចុះនៅក្រោមចំណុចគោលកំណត់ឬមានហានិភ័យនៃការធ្លាក់ចុះក្រោមចំណុចគោល សកម្មភាពគ្រប់គ្រងនិងអភិរក្សត្រូវបានផ្តួចផ្តើមឡើងក្នុងគោលបំណងជួយសម្រួលដល់ការស្តារឡើងវិញនូវផលស្តុកទាំងនោះ។ យុទ្ធសាស្ត្រគ្រប់គ្រងជលផលត្រូវធានាថាចំណុចគោលរបស់គោលដៅ មិនត្រូវលើសពីចំណុចជាមធ្យមទេ។

៦. ក្នុងពេលដែលព័ត៌មានក្នុងការកំណត់ចំណុចគោលសម្រាប់ការនេសាទមានភាពមិនគ្រប់គ្រាន់ ឬគ្មានសោះ ចំណុចគោលបណ្តោះអាសន្នមួយគួរត្រូវបានកំណត់ឡើង។ ចំណុចគោលបណ្តោះអាសន្ននេះ អាចត្រូវបានបង្កើតឡើងដោយភាពស្រដៀងគ្នាទៅនឹងផលស្តុកប្រហាក់ប្រហែលគ្នាឬដែលបានដឹងច្បាស់លាស់។ នៅក្នុងស្ថានភាពបែបនោះ ការនេសាទគឺជាប្រធានបទដែលត្រូវបង្កើនការតាមដាន ដើម្បីមានលទ្ធភាពកែសម្រួលឡើងវិញនូវចំណុចគោលបណ្តោះអាសន្នជាព័ត៌មានដែលមានភាពប្រសើរឡើងអាចរកបាន។

៧. អត្រាបាត់បង់ត្រីនៅពេលនេសាទ ដែលអាចគណនាជាទិន្នផលនេសាទនិរន្តរភាពអតិបរមា គួរត្រូវបានកំណត់ថាជាបទដ្ឋានអប្បបរមាសម្រាប់កំណត់ចំណុចគោល។ ចំពោះផលស្តុកដែលមិនត្រូវបាននេសាទហួសកម្រិត យុទ្ធសាស្ត្រគ្រប់គ្រងជលផលត្រូវធានាថាអត្រាបាត់បង់ត្រីពីការនេសាទមិនត្រូវលើសពីអ្វីដែលឆ្លើយតបទៅនឹងទិន្នផលនិរន្តរភាពអតិបរមា ហើយជីវម៉ាស់មិនត្រូវធ្លាក់ចុះក្រោមកម្រិតចាប់ផ្តើមដែលបានកំណត់ជាមុននោះទេ។ ចំពោះផលស្តុក ដែលរងការនេសាទលើសកម្រិត ជីវម៉ាស់ ដែលនឹងផលិតបាន ទិន្នផលនិរន្តរភាពអតិបរមាអាចបម្រើជាគោលដៅស្តារឡើងវិញ។

# ឧបសម្ព័ន្ធទី៣.ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រ កម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀង សម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រចុះថ្ងៃទី១០  ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រងនិងការអភិរក្ស ផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

ព្រះរាជក្រម

នស/រកម/០១២០/០០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
## ស្ដីពី
## ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិ ស្ដីពីច្បាប់សមុទ្រចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

**មាត្រា១.-**

អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិស្ដីពីច្បាប់សមុទ្រចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ដែលបានអនុម័តដោយសន្និសីទអង្គការសហប្រជាជាតិ នៅក្រុងញូយ៉កនៃសហរដ្ឋអាមេរិក នាថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៩៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃសៅរ៍ ៩រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២០

នស/រកម/០១២០/០០៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

រៀបចំបកប្រែ និងបោះពុម្ពដោយ ៖
រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការបោះពុម្ពផ្សាយនេះ ត្រូវបានផលិតឡើង ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុ
ពីសហភាពអឺរ៉ុប។ ខ្លឹមសារជាការទទួលខុសត្រូវតែមួយគត់របស់
រដ្ឋបាលជលផលហើយមិនឆ្លុះបញ្ចាំងពី
ទស្សនៈរបស់សហភាពអឺរ៉ុបទេ។